# មាតិកា

## I_ខុទ្ទកាល័យព្រះមហាក្សត្រ

### ១_ព្រះរាជក្រម

១៣-១០-២០០៥ -ព្រះរាជក្រម នស/រកម/១០០៥/០២៧ ស្តីពីការប្រកាសឱ្យប្រើច្បាប់ស្តីពីការអនុម័តយល់ព្រមឱ្យ ព្រះរាជាណាចក្រកម្ពុជា ចូលជាភាគីនៃអនុសញ្ញាអន្តរជាតិស្តីពី ការបង្ក្រាបការដាក់គ្រាប់បែកផ្ទុះរបស់ភេរវករ ៦២៨៧

១៣-១០-២០០៥ -ព្រះរាជក្រម នស/រកម/១០០៥/០២៨ ស្តីពីការប្រកាសឱ្យប្រើច្បាប់ស្តីពីការអនុម័តយល់ព្រមឱ្យ ព្រះរាជាណាចក្រកម្ពុជា ចូលជាសមាជិកនៃអនុសញ្ញាអន្តរជាតិប្រឆាំងនឹងការចាប់ជាចំណាប់ខ្មាំង ៦៣១៥

### ២_ព្រះរាជក្រឹត្យ

១៧-១០-២០០៥ -ព្រះរាជក្រឹត្យ នស/រកត/១០០៥/៤៣៦ ស្តីពីការប្រោសព្រះរាជទានចំពោះ លោក **ខេង សុមេធ** នូវ **គ្រឿងឥស្សរិយយស ព្រះរាជាណាចក្រកម្ពុជា** ថ្នាក់ **សេនា** ៦៣៣៣

២០-១០-២០០៥ -ព្រះរាជក្រឹត្យ នស/រកត/១០០៥/៤៤០ ស្តីពីការតែងតាំងឯកឧត្តម **ស៊ឹម កុកហេង** ជាទីប្រឹក្សាអមរាជរដ្ឋាភិបាល មានឋានៈស្មើ **រដ្ឋលេខាធិការ** ៦៣៣៤

២០-១០-២០០៥ -ព្រះរាជក្រឹត្យ នស/រកត/១០០៥/៤៤១ ស្តីពីការតែងតាំងឯកឧត្តម **ហែម យឹមអេង** ជាទីប្រឹក្សាអមក្រសួងសាធារណការ និងដឹកជញ្ជូន មានឋានៈស្មើ **អនុរដ្ឋលេខាធិការ** ៦៣៣៥

២០-១០-២០០៥ -ព្រះរាជក្រឹត្យ នស/រកត/១០០៥/៤៤២ ស្តីពីការតែងតាំងឯកឧត្តម **ស សិទ្ធិ** ជាទីប្រឹក្សាផ្ទាល់សម្តេច **នរោត្តម សិរីវុឌ្ឍ** ឧបនាយករដ្ឋមន្ត្រី មានឋានៈស្មើ **រដ្ឋលេខាធិការ** ដោយមិនទទួលប្រាក់បៀវត្ស បន្ថែមលើមុខងារបច្ចុប្បន្ន ៦៣៣៦

២០-១០-២០០៥ -ព្រះរាជក្រឹត្យ នស/រកត/១០០៥/៤៤៣ ស្តីពីការតែងតាំងឯកឧត្តម **សៅ សុខា** ជាទីប្រឹក្សាផ្ទាល់សម្តេចនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា មានឋានៈស្មើ **រដ្ឋលេខាធិការ** បន្ថែមលើមុខងារបច្ចុប្បន្ន ៦៣៣៧

| | | |
|---|---|---|
| ២៣-១០-២០០៥ | -ព្រះរាជក្រឹត្យ នស/រកត/១០០៥/៤៤៤ ស្ដីពីការកែសំរួលមាត្រា ៨ មាត្រា ១០ នៃព្រះរាជក្រឹត្យលេខ នស/រកត/០៥០១/១៧៨ ចុះថ្ងៃទី ២២ ខែ ឧសភា ឆ្នាំ ២០០១ ស្ដីពីលក្ខន្តិកៈដោយឡែកនៃក្របខ័ណ្ឌមន្ត្រីនគរបាលជាតិកម្ពុជា | ៦៣៣៨ |
| ២៣-១០-២០០៥ | -ព្រះរាជក្រឹត្យ នស/រកត/១០០៥/៤៤៥ ស្ដីពីការបំពាក់ **គ្រឿងឥស្សរិយយស ព្រះរាជាណាចក្រកម្ពុជា** តាមលំដាប់ថ្នាក់ជូននាយនគរបាលជាតិជាន់ខ្ពស់ នៃក្រសួងមហាផ្ទៃ ចំនួន ៣០២ រូប ដែលមានស្នាដៃក្នុងការបំរើជាតិមាតុភូមិ | ៦៣៤០ |
| ២៣-១០-២០០៥ | -ព្រះរាជក្រឹត្យ នស/រកត/១០០៥/៤៤៦ ស្ដីពី :<br>១-ត្រូវបានតម្លើងឋានៈឯកឧត្តម **ទៃ នរសត្យា** ទីប្រឹក្សាផ្ទាល់សម្ដេចនាយករដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាលកម្ពុជា មានឋានៈស្មើ **រដ្ឋលេខាធិការ**<br>២- ត្រូវបានតែងតាំងឯកឧត្តម **ជុំ កុសល** ជាទីប្រឹក្សាផ្ទាល់សម្ដេចនាយករដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាលកម្ពុជា មានឋានៈស្មើ **អនុរដ្ឋលេខាធិការ** | ៦៣៥១ |
| ២៣-១០-២០០៥ | -ព្រះរាជក្រឹត្យ នស/រកត/១០០៥/៤៤៧ ស្ដីពីការតែងតាំងឯកឧត្តម **មី សាមីឌី** ជាទីប្រឹក្សារាជរដ្ឋាភិបាលកម្ពុជា មានឋានៈស្មើ **ទេសរដ្ឋមន្ត្រី** បន្ថែមលើមុខងារបច្ចុប្បន្ន | ៦៣៥២ |


## II-រាជរដ្ឋាភិបាល

### ១-អនុក្រឹត្យ


| | | |
|---|---|---|
| ២៤-១០-២០០៥ | -អនុក្រឹត្យលេខ ១២២ អនក្រ.បក ស្ដីពីការផ្ទេរឥណទានថវិកា | ៦៣៥៣ |
| ២៤-១០-២០០៥ | -អនុក្រឹត្យលេខ ១២៣ អនក្រ.បក ស្ដីពីការបង្កើតមជ្ឈមណ្ឌលសហប្រតិបត្តិការកម្ពុជា-ជប៉ុន | ៦៣៥៥ |
| ២៥-១០-២០០៥ | -អនុក្រឹត្យលេខ ១២៤ អនក្រ.បក ស្ដីពីការផ្ទេរឥណទានថវិកា | ៦៣៥៨ |
| ២៤-១០-២០០៥ | -អនុក្រឹត្យលេខ ៧៩៦ អនក្រ.តត ស្ដីពីការប្រគល់ភារកិច្ចជូនមន្ត្រីរាជការ | ៦៣៦០ |
| ២៤-១០-២០០៥ | -អនុក្រឹត្យលេខ ៧៩៧ អនក្រ.តត ស្ដីពីការជូនមេដាយមុនីសារាភ័ណ្ឌ | ៦៣៦១ |
| ២៤-១០-២០០៥ | -អនុក្រឹត្យលេខ ៧៩៨ អនក្រ.តត ស្ដីពីការជូនមេដាយការងារ | ៦៣៦២ |
| ២៤-១០-២០០៥ | -អនុក្រឹត្យលេខ ៧៩៩ អនក្រ.តត ស្ដីពីការជូនមេដាយស្ថាបនាជាតិ | ៦៣៦៦ |
| ២៤-១០-២០០៥ | -អនុក្រឹត្យលេខ ៨០០ អនក្រ.តត ស្ដីពីការជូនមេដាយសហមេត្រី | ៦៣៦៧ |
| ២៤-១០-២០០៥ | -អនុក្រឹត្យលេខ ៨០១ អនក្រ.តត ស្ដីពីការជូនមេដាយស្ថាបនាជាតិ | ៦៣៦៨ |

២៥-១០-២០០៥ -អនុក្រឹត្យលេខ ៨០២ អនក្រ.តត ស្ដីពីការផ្ទេរភារកិច្ច និងតែងតាំងមុខតំណែងនាយនគរបាលជាតិ ៦៣៦៩

២៦-១០-២០០៥ -អនុក្រឹត្យលេខ ៨០៣ អនក្រ.តត ស្ដីពីការជូនមេដាយស្ថាបនាជាតិ ៦៣៧០

២៦-១០-២០០៥ -អនុក្រឹត្យលេខ ៨០៤ អនក្រ.តត ស្ដីពីការជូនមេដាយស្ថាបនាជាតិ ៦៣៧១

២៨-១០-២០០៥ -អនុក្រឹត្យលេខ ៨០៥ អនក្រ.តត ស្ដីពីការជូនមេដាយស្ថាបនាជាតិ ៦៣៧៣

២៨-១០-២០០៥ -អនុក្រឹត្យលេខ ៨០៦ អនក្រ.តត ស្ដីពីការជូនមេដាយមុនីសារាភ័ណ្ឌ ៦៣៧៤

២៨-១០-២០០៥ -អនុក្រឹត្យលេខ ៨០៧ អនក្រ.តត ស្ដីពីការជូនមេដាយមុនីសារាភ័ណ្ឌ ៦៣៧៦

## ២_សេចក្ដីសំរេច

២៤-១០-២០០៥ -សេចក្ដីសំរេចលេខ ៤៣ សសរ ស្ដីពីការបង្កើតក្រុមអធិការកិច្ចអន្តរក្រសួង ដើម្បីត្រួតពិនិត្យលើលទ្ធផលនៃការសិក្សាស្រាវជ្រាវធនធានរ៉ែ របស់ក្រុមហ៊ុនទាំងអស់ដែលបានទទួលគោលការណ៍រួចហើយ ពីក្រសួង-ស្ថាប័នមានសមត្ថកិច្ច ៦៣៧៧

២៧-១០-២០០៥ -សេចក្ដីសំរេចលេខ ៤៤ សសរ ស្ដីពីការបង្កើតគណៈកម្មការរៀបចំពិព័រណ៍វប្បធម៌ពិភពលោក អង្គរ-ឃ្យុងយូ ២០០៦ (Organizing Committee for Angkor-Gyeongju World Cultural Expo 2006) នៅខេត្តសៀមរាប ឆ្នាំ ២០០៦-២០០៧ ៦៣៨០

២៧-១០-២០០៥ -សេចក្ដីសំរេចលេខ ៤៥ សសរ ស្ដីពីការបង្កើតក្រុមការងាររៀបចំក្បួនរថយន្ត Caravan Tour ពីបាងកក-ភ្នំពេញ-ហូជីមិញ ក្នុងក្របខ័ណ្ឌកិច្ចសហប្រតិបត្តិការ ACMECS និង GMS ៦៣៨២

២៧-១០-២០០៥ -សេចក្ដីសំរេចលេខ ៤៦ សសរ ស្ដីពីការកែសម្រួលប្រការ ២ នៃសេចក្ដីសម្រេចលេខ ៧៧ សសរ ចុះថ្ងៃទី ២៥ ខែ វិច្ឆិកា ឆ្នាំ ១៩៩៩ ស្ដីពីការបង្កើតចំណុចការងារសម្រាប់តាមដានរបាយការណ៍របស់ក្រសួងកសិកម្ម រុក្ខា ប្រមាញ់ និងនេសាទ និងក្រសួងបរិស្ថាន ៦៣៨៧

៣១-១០-២០០៥ -សេចក្ដីសំរេចលេខ ៤៧ សសរ ស្ដីពីការផ្ទេរសិទ្ធិការងាររបស់រាជរដ្ឋាភិបាល ៦៣៨៩

# III_ការងារបណ្ដាក្រសួង

## ១_ទីស្ដីការរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

១១-១០-២០០៥ -ប្រកាសអន្តរក្រសួងលេខ ៦៥៧ សហវ ស្ដីពីការអនុញ្ញាតឱ្យសេវាសុខាភិបាលអនុវត្តការពិនិត្យ និងព្យាបាលជំងឺដោយ យកកំរៃខ្លះពីអ្នកជំងឺ ៦៣៩០

២០-១០-២០០៥ -ប្រកាសលេខ ៦៨៦ សហវ.ប្រក ស្ដីពីការកែសម្រួលសមាសភាពគណៈកម្មការអន្តរក្រសួង ដើម្បីចុះពិនិត្យ និងវាយតម្លៃលើផលប៉ះពាល់ដល់សំណង់ផ្ទះសំបែង ដីធ្លី ប្រជារាស្ត្រដោយសារគំរោងការអភិវឌ្ឍន៍ ទេសចរណ៍ មេគង្គ ៦៣៩៣

២១-១០-២០០៥ -ប្រកាសលេខ ៦៩០ សហវ.ប្រក.៣៨ ស្ដីពីការបែងចែកប្រាក់រង្វាន់នៃការប្រមូលពន្ធមធ្យោបាយដឹកជញ្ជូន និង យានជំនិះគ្រប់ប្រភេទសំរាប់ឆ្នាំ ២០០៥ ៦៣៩៥

២៤-១០-២០០៥ -ប្រកាសលេខ ៦៩៦ សហវ.ប្រក ស្ដីពីការបង្កើតគណៈកម្មការបញ្ជីសារពើភ័ណ្ឌទ្រព្យសម្បត្តិរដ្ឋ ប្រចាំក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ៦៣៩៨

## ២_ទីស្តីការរដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល

១២-១០-២០០៥ -ប្រកាសលេខ ៧៧១ ឧរថ.កឧ.ប្រក ស្ដីពីការអនុញ្ញាតឱ្យក្រុមហ៊ុន វ៉ាយថិច ហ្គាមេន (ខេមបូឌា) បង្កើតរោងចក្រ "កាត់ដេរសម្លៀកបំពាក់" ដែលមាន ឈ្មោះថា "វ៉ាយថិច ហ្គាមេន (ខេមបូឌា)" ៦៤០១

១៨-១០-២០០៥ -ប្រកាសលេខ ៧៨១ ឧរថ.កឧ.ប្រក ស្ដីពីការអនុញ្ញាតឱ្យក្រុមហ៊ុន អ៊ីសធើនសាន់ចឺប៊ែកខូ បង្កើតរោងចក្រ "ផលិតបារី" ដែលមាន ឈ្មោះថា "អ៊ីសធើនសាន់ចឺប៊ែកខូ" ៦៤០៣

១៩-១០-២០០៥ -ប្រកាសលេខ ៧៩៤ ឧរថ.កឧ.ប្រក ស្ដីពីការអនុញ្ញាតឱ្យក្រុមហ៊ុន រេនបូ ស្ត្រីន ព្រីងធីង ភីធីអ៊ី អិលធីឌី បង្កើតរោងចក្រ "បោះពុម្ពសម្លៀកបំពាក់" ដែលមាន ឈ្មោះថា "រេនបូ ស្ត្រីន ព្រីងធីង ភីធីអ៊ី អិលធីឌី" ៦៤០៥

២៥-១០-២០០៥ -ប្រកាសលេខ ៨០៩ ឧរថ.កឧ.ប្រក ស្ដីពីការអនុញ្ញាតឱ្យក្រុមហ៊ុន ស៊ាង ទូ (ខេមបូឌា) មេឌីខល អេឃ្វីបមេន បង្កើតរោងចក្រ "ផលិតសំភារៈបរិក្ខារពេទ្យ" ដែលមាន ឈ្មោះថា "ស៊ាង ទូ (ខេមបូឌា) មេឌីខល អេឃ្វីបមេន" ៦៤០៧

២៥-១០-២០០៥ -ប្រកាសលេខ ៨១០ ឧរថ.កឧ.ប្រក ស្ដីពីការអនុញ្ញាតឱ្យក្រុមហ៊ុន ចាង តៃ អ៊ិនធើណេសិនណល ខប បង្កើតរោងចក្រ "កាត់ដេរសម្លៀកបំពាក់" ដែលមានឈ្មោះថា "ចាង តៃ អ៊ិនធើណេសិនណល ខប" ៦៤០៩

២៥-១០-២០០៥ -ប្រកាសលេខ ៨១១ ឧរថ.កឧ.ប្រក ស្ដីពីការអនុញ្ញាតឱ្យក្រុមហ៊ុន មិញ ហ៊ុយ ហ្គាមេន បង្កើតរោងចក្រ "កាត់ដេរសម្លៀកបំពាក់" ដែលមានឈ្មោះថា "មិញ ហ៊ុយ ហ្គាមេន" ៦៤១១

២៥-១០-២០០៥ -ប្រកាសលេខ ៨១២ ឧរថ.កឧ.ប្រក ស្តីពីការអនុញ្ញាតឱ្យក្រុមហ៊ុន ឌី អឹម អេ (ខេមបូឌា) បង្កើតរោងចក្រ "កាត់ដេរសម្លៀកបំពាក់" ដែលមានឈ្មោះថា "ឌី អឹម អេ (ខេមបូឌា)" ៦៤១៣

## ៣-ទីស្តីការរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

១៨-១០-២០០៥ -ប្រកាសលេខ ១៤៣៣ ប្រក ស្តីពីការប្រើប្រាស់ផ្លាកលេខថ្មីសំគាល់យានជំនិះ និងជលយាននគរបាលជាតិ និងការគ្រប់គ្រងបញ្ជីប័ណ្ណសំគាល់យានជំនិះគ្រប់ប្រភេទ ៦៤១៥

## ៤-ទីស្តីការរដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

០៧-១០-២០០៥ -លិខិតលេខ ២២៩១ ពណ.នតក ស្តីពី ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្មរបស់ក្រុមហ៊ុន **ខេង ស្រ៊ី** ៦៤២០

០៧-១០-២០០៥ -លិខិតលេខ ២២៩៧ ពណ.នតក ស្តីពី ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្មរបស់ក្រុមហ៊ុន **សុខឡុង ខូ អិលធីឌី** ៦៤២២

០៧-១០-២០០៥ -លិខិតលេខ ២២៩៨ ពណ.នតក ស្តីពី ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្មរបស់ក្រុមហ៊ុន **ស៊ីន លីច ហ៊ាំ អ៊ិនធើណេសិនណាល ខមមើសល ខមភេនី** ៦៤២៤

០៧-១០-២០០៥ -លិខិតលេខ ២២៩៩ ពណ.នតក ស្តីពី ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្មរបស់ក្រុមហ៊ុន **អាត ជេខរ & អ៊ែតវើថាយស៊ីង** ៦៤២៦

០៧-១០-២០០៥ -លិខិតលេខ ២៣០០ ពណ.នតក ស្តីពី ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្មរបស់ក្រុមហ៊ុន **ស៊ីកសេស អិចប្រេស គ្រេឌីង** ៦៤២៨

០៧-១០-២០០៥ -លិខិតលេខ ២៣០១ ពណ.នតក ស្តីពី ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្មរបស់ក្រុមហ៊ុន **លី ឌា ស្រេង ខូ អិលធីឌី** ៦៤៣០

១០-១០-២០០៥ -លិខិតលេខ ២៣០៤ ពណ.នតក ស្តីពី ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្មរបស់ក្រុមហ៊ុន **ចាង តៃ អ៊ិនធើណេសិនណាល ខប** ៦៤៣២

១០-១០-២០០៥ -លិខិតលេខ ២៣០៥ ពណ.នតក ស្តីពី ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្មរបស់ក្រុមហ៊ុន **ឈាន់ទ៉ារី ខនស្ត្រាក់សិន គ្រុប** ៦៤៣៣

១០-១០-២០០៥ -លិខិតលេខ ២៣០៦ ពណ.នតក ស្តីពី ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្មរបស់ក្រុមហ៊ុន **ហេបភី ស្ពាយ** ៦៤៣២

| | | |
|---|---|---|
| ១០-១០-២០០៥ | -លិខិតលេខ ២៣០៩ ពណ.នតក ស្តីពី ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្មរបស់ក្រុមហ៊ុន **កែច ចាន់ដារ៉ា** | ៦៤៣៧ |
| ១០-១០-២០០៥ | -លិខិតលេខ ២៣១២ ពណ.នតក ស្តីពី ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្មរបស់ក្រុមហ៊ុន **អ៊ីចន ម៉ាលីស អិលធីឌី** | ៦៤៣៩ |
| ១១-១០-២០០៥ | -លិខិតលេខ ២៣១៤ ពណ.នតក ស្តីពី ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្មរបស់ក្រុមហ៊ុន **ជេ ជេ តី អ៊ីនធើណេសិនណាល ឌីវេឡុបមេន អេន ត្រេដ អ៊ីន** | ៦៤៤១ |
| ១១-១០-២០០៥ | -លិខិតលេខ ២៣១៥ ពណ.នតក ស្តីពី ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្មរបស់ក្រុមហ៊ុន **ម៉ាស្ទ័រ ប្រ៊ីហ្វេសិនណាល ស៊ីឃ្យូរីធី ខូ អិលធីឌី (អិម តី អេស)** | ៦៤៤៣ |
| ១១-១០-២០០៥ | -លិខិតលេខ ២៣១៦ ពណ.នតក ស្តីពី ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្មរបស់ក្រុមហ៊ុន **ម៉ា_គីម ឌីវេឡុបមេន អេន ត្រេដ អ៊ីន** | ៦៤៤៥ |
| ១១-១០-២០០៥ | -លិខិតលេខ ២៣១៧ ពណ.នតក ស្តីពី ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្មរបស់ក្រុមហ៊ុន **អិចប្រេស មើនិន (ខេមបូឌា)** | ៦៤៤៧ |
| ១១-១០-២០០៥ | -លិខិតលេខ ២៣១៨ ពណ.នតក ស្តីពី ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្មរបស់ក្រុមហ៊ុន **កែប ផៅវ័រ ស៊ីបផ្លាយ** | ៦៤៤៩ |

# ព្រះរាជក្រម

នស/រកម/១០០៥/០២៧

## យើង

## ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយ របស់សម្តេចនាយករដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាលកម្ពុជា និងរបស់សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

## ប្រកាសឱ្យប្រើ

ច្បាប់ស្តីពីការអនុម័តយល់ព្រម ឱ្យព្រះរាជាណាចក្រកម្ពុជាចូលជាភាគី នៃអនុសញ្ញាអន្តរជាតិស្តីពីការបង្ក្រាបការដាក់គ្រាប់បែកផ្ទុះរបស់ភេរវករ ដែលរដ្ឋសភាបានអនុម័តកាលពីថ្ងៃទី ២៥ ខែ សីហា ឆ្នាំ ២០០៥ នាសម័យប្រជុំរដ្ឋសភាលើកទី ៣ នីតិកាលទី ៣ និងព្រឹទ្ធសភាបានអនុម័តយល់ស្របលើទម្រង់ និងគតិនៃច្បាប់នេះទាំងស្រុងកាលពីថ្ងៃទី ០៧ ខែ កញ្ញា ឆ្នាំ ២០០៥ នាសម័យប្រជុំពេញអង្គលើកទី ១០ នីតិកាលទី ១ ដែលមានសេចក្តីទាំងស្រុងដូចតទៅនេះ :

# ច្បាប់

# ស្តីពី

# ការអនុម័តយល់ព្រមឱ្យព្រះរាជាណាចក្រកម្ពុជាចូលជាភាគី នៃអនុសញ្ញាអន្តរជាតិស្តីពីការបង្ក្រាប ការដាក់គ្រាប់បែកផ្ទុះរបស់ភេរវករ

**មាត្រា ១.–**

អនុម័តយល់ព្រមឱ្យព្រះរាជាណាចក្រកម្ពុជាចូលជាភាគីនៃអនុសញ្ញាអន្តរជាតិស្តីពីការបង្ក្រាបការដាក់គ្រាប់បែកផ្ទុះរបស់ភេរវករ ដែលអនុម័តដោយមហាសន្និបាតអង្គការសហប្រជាជាតិនាសម័យប្រជុំពេញអង្គលើកទី ៧២ នាថ្ងៃទី ១៥ ខែ ធ្នូ ឆ្នាំ ១៩៩៧ ហើយដែលមានអត្ថបទទាំងស្រុងភ្ជាប់មកជាមួយនេះ ។

**មាត្រា ២.–**

រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា ត្រូវបន្តរាល់នីតិវិធីដើម្បីអនុវត្តអនុសញ្ញានេះ ។

**មាត្រា ៣.–**

ច្បាប់នេះត្រូវបានប្រកាសជាការប្រញាប់ ។

ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ ថ្ងៃទី ១៧ ខែ តុលា ឆ្នាំ ២០០៥

នស/រកម.១០០៥.០២៧ **ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**

**នរោត្តម សីហមុនី**

បានយកសេចក្ដីក្រាបបង្គំទូលថ្វាយ

សូមឡាយព្រះហស្តលេខាព្រះមហាក្សត្រ

**នាយករដ្ឋមន្ត្រី**

**ហត្ថលេខា ,**

**ហ៊ុន សែន**

បានជម្រាបជូនសម្ដេចនាយករដ្ឋមន្ត្រី

**សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ**

**ហត្ថលេខា ព្រះហស្តលេខា**

**ស ខេង នរោត្តម សិរីវុឌ្ឍ**

លេខ ៥៦០ ច.ល

ដើម្បីចម្លងចែកផ្សាយ

រាជធានីភ្នំពេញ ថ្ងៃទី ១៩ ខែ តុលា ឆ្នាំ ២០០៥

**អគ្គលេខាធិការរាជរដ្ឋាភិបាល**

**សុខ ចិន្តាសោភា** 

**ស៊ុំ ម៉ានិត**

សេចក្តីសំរេចអនុមត័ដោយមហាសន្និបាត

(របាយការណ៍របស់គណកម្មាធិការទី ៦ (អា/៥២/៦៥៣))

៥២/១៦៤. អនុសញ្ញាអន្តរជាតិស្តីអំពីការបង្ក្រាបការដាក់ជាតិផ្ទុះរបស់ភេរវករ

*មហាសន្និបាត*

រំលឹកឡើងវិញនូវសេចក្តីសំរេចរបស់ខ្លួន ៤៩/៦០ ថ្ងៃទី ៩ ខែ ធ្នូ ១៩៩៤ ដែលខ្លួនបានអនុម័តលើសេចក្តីប្រកាសស្តីអំពីវិធានការលុបបំបាត់អំពើភេរវកម្មអន្តរជាតិ និង សេចក្តីសំរេចរបស់ខ្លួន ៥១/២១០ ចុះថ្ងៃទី ១៧ ខែ ធ្នូ ១៩៩៦ ។

ដោយបានពិចារណាលើឯកសារពង្រាងអនុសញ្ញាក្នុងការបង្ក្រាបលើការដាក់ជាតិផ្ទុះរបស់ភេរវករ ដែលរៀបចំដោយគណកម្មាធិការពិសេសរបស់ខ្លួនដែលបង្កើតឡើងដោយសេចក្តីសំរេចរបស់មហាសន្និបាត ៥១/២១០ ចុះថ្ងៃទី ១៧ ធ្នូ ១៩៩៦ និង ក្រុមការងាររបស់គណកម្មាធិការទីប្រាំមួយ[១] ៖

១. អនុម័តអនុសញ្ញាអន្តរជាតិស្តីអំពីការបង្ក្រាបការដាក់គ្រាប់បែកផ្ទុះភ្ជាប់ទៅនឹងសេចក្តីសំរេចបច្ចុប្បន្ន និង សំរេចបើកចំហរសំរាប់ការចុះហត្ថលេខានៅទីស្នាក់ការរបស់អង្គការសហប្រជាជាតិនៅ ញូយ៉ក ចាប់ពីថ្ងៃទី ១២ ខែ មករា ១៩៩៨ ដល់ ៣១ ធ្នូ ១៩៩៩ ។

២. ស្នើសុំដល់រដ្ឋទាំងអស់ចុះហត្ថលេខា និង ធ្វើសច្ចាប័ន ទទួលយក ឬ ឯកភាព ឬដាក់បន្ថែមទៅនឹងអនុសញ្ញា ។

កិច្ចប្រជុំសាធារណៈទី ៧២

១៥ ធ្នូ ១៩៩៧

[1] See Official Records of the General Assembly, Fifty-second Session, Supplement No. 37 (A/52/37).

# ឧបសម្ព័ន្ធ

## អនុសញ្ញាអន្តរជាតិស្តីអំពីការបង្រ្កាបការដាក់គ្រាប់បែកផ្ទុះរបស់ភេរវករ

ភាគីរដ្ឋក្នុងអនុសញ្ញានេះ

បានយល់ឃើញពីគោលបំណង និង គោលការណ៍អំពីរដ្ឋធម្មនុញ្ញរបស់អង្គការសហប្រជាជាតិទាក់ទងនឹងការថែរក្សាសន្តិភាពអន្តរជាតិ និង សន្តិសុខ និង ការបង្កើនទំនាក់ទំនងក្នុងភាពជាអ្នកជិតខាងល្អ និង ជាមិត្តភាព និង កិច្ចសហប្រតិបត្តិការក្នុងចំណោមរដ្ឋ ។

ដោយមានការព្រួយបារម្ភយ៉ាងខ្លាំងអំពីការកើនឡើងនូវសកម្មភាពភេរវកម្មគ្រប់ទំរង់ និង គ្រប់រូបភាព ។

ដោយរំលឹកឡើងវិញលើសេចក្តីប្រកាសក្នុងឱកាសខួបលើកទី ៥០ របស់អង្គការសហប្រជាជាតិ នៅថ្ងៃទី ២៤ ខែ តុលា ១៩៩៥ ។[២]

ដោយរំលឹកឡើងវិញផងដែរលើសេចក្តីប្រកាសស្តីអំពីវិធានការដើម្បីលុបបំបាត់អំពើភេរវកម្មអន្តរជាតិ ដោយភ្ជាប់ទៅនឹងសេចក្តីសំរេចរបស់មហាសន្និបាត ៤៩/៦០ ចុះថ្ងៃទី ៩ ខែ ធ្នូ ១៩៩៤ ដែលក្នុងនោះ "រដ្ឋសមាជិករបស់អង្គការសហប្រជាជាតិបានបញ្ជាក់យ៉ាងឱឡារិកនូវការថ្កោលទោសជាឯកច្ឆន្ទរាល់អំពើ វិធីសាស្ត្រ និង ការប្រព្រឹត្តិរបស់ភេរវករថាជាជនល្មើស និង គ្មានហេតុផល ទោះធ្វើឡើងនៅទីកន្លែងណា ឬ ដោយអ្នកណាក៏ដោយរួមទាំងអ្វីៗដែលធ្វើអោយរាំងស្ទះដល់ទំនាក់ទំនងជាមិត្តភាពក្នុងបណ្តារដ្ឋ និង ប្រជាជន និង គំរាមកំហែងដល់បូរណភាពដែនដី និង សន្តិសុខរបស់រដ្ឋ" ។

ដោយកត់សំគាល់ឃើញថាសេចក្តីប្រកាសក៏បានលើកទឹកចិត្តដល់រដ្ឋ "អោយធ្វើការពិនិត្យឡើងវិញជាបន្ទាន់លើវិសាលភាពនៃបញ្ញត្តិច្បាប់អន្តរជាតិដែលមានចែងអំពីការបង្ការទុបស្កាត់ ការបង្រ្កាប និង ការលុបបំបាត់

---

[2] See resolution 50/6.

អំពើភេរវកម្មគ្រប់រូបភាពសំដៅកំណត់អោយបានថាមានគោលការច្បាប់ដ៏ទូលំលាយមួយដែលលើកឡើងរាល់ចំនុចនានាដែលទាក់ទងនឹងបញ្ហានេះ ។

ដោយរំលឹកឡើងវិញអំពីសេចក្តីសំរេច ៥១/២១០ ចុះថ្ងៃទី ១៧ ខែ ធ្នូ ១៩៩៦ និង សេចក្តីប្រកាសបន្ថែម គឺ សេចក្តីប្រកាស ១៩៩៤ ស្តីអំពីវិធានការដើម្បីលុបបំបាត់អំពើភេរវកម្មដែលតទៅភ្ជាប់នឹងឧបសម្ពន្ធ័នេះ ។

ដោយកត់សំគាល់ឃើញថាការវាយប្រហាររបស់ភេរវករដោយមធ្យោបាយដាក់ជាតិផ្ទុះ ឬ ឧបករណ៍ដែលមានគ្រោះថ្នាក់ដល់ជីវិតផ្សេងៗទៀតបានកើនឡើងយ៉ាងឆាប់រហ័ស ។

ដោយកត់សំគាល់ឃើញផងដែរថាបញ្ញត្តិច្បាប់ពហុភាគីដែលមានរួចហើយមិនបានលើកឡើងអំពីការវាយប្រហារទាំងនេះអោយបានសមស្រប ។

ដោយមានជំនឿថាត្រូវការបង្កើនកិច្ចសហប្រតិបត្តិការអន្តរជាតិជាបន្ទាន់រវាងរដ្ឋក្នុងការរៀបចំឡើង និង អនុម័តយកវិធានការដែលមានប្រសិទ្ធិភាពក្នុងការទុបស្កាត់បង្ការអំពើភេរវកម្មទាំងនេះ និង ដើម្បីធ្វើការកាត់ទោស និង ផ្តន្ទាទោសជនល្មើស ។

ដោយយល់ឃើញថាការកើតឡើងនូវអំពើទាំងនេះគឺជាការព្រួយបារម្ភយ៉ាងខ្លាំងរបស់សហគមអន្តរជាតិទាំងមូល ។

ដោយកត់សំគាល់ឃើញថាសកម្មភាពរបស់កំលាំងយោធារបស់រដ្ឋត្រូវគ្រប់គ្រងដោយក្រមច្បាប់អន្តរជាតិខាងក្រៅពីគោលការណ៍របស់អនុសញ្ញានេះ និង ថាការមិនដាក់បញ្ចូលនូវវិធានការមួយចំនួនក្នុងអនុសញ្ញានេះមិនអត់អោន ឬ ធ្វើអោយស្របច្បាប់នូវអំពើណាមួយដែលខុសនឹងច្បាប់ ឬ បង្អាក់ការចោទប្រកាន់ក្រោមច្បាប់ដ៏ទៃៗទៀត ។

*បានព្រមព្រៀងដូចតទៅ:*

មាត្រា ១

ដើម្បីគោលបំណងនៃអនុសញ្ញានេះ:

១. "ឧបករណ៍រដ្ឋាភិបាល ឬ ឧបករណ៍រដ្ឋ រួមទាំងឧបករណ៍បន្ទោះអាសន្ន ឬ អចិន្ត្រៃយ៍ ឬ គ្រឿងដឹកនាំ ដែលប្រើ ឬ កាន់កាប់ដោយតំណាងរបស់រដ្ឋមួយ ដោយសមាជិករបស់រដ្ឋាភិបាល និតិបញ្ញត្តិ ឬ តុលាការ ឬ ដោយ មន្ត្រី ឬ និយោជិករបស់រដ្ឋមួយ ឬ សមត្ថកិច្ចសាធារណៈផ្សេងៗ ឬ អង្គភាព ឬ ដោយនិយោជិត ឬ មន្ត្រីរបស់អង្គការអន្តរជាតិទាក់ទងនឹងភារៈកិច្ចជាផ្លូវការរបស់ពួកគេ ។

២. "ឧបករណ៍ហេដ្ឋារចនាសម្ព័ន្ធ" មានន័យថារាល់ឧបករណ៍ដែលជាកម្មសិទ្ធិរបស់ឯកជន ឬ សាធារណៈ ដែលផ្តល់ ឬ បែងចែកសេវាសំរាប់ជាផលប្រយោជន៍សាធារណៈ ដូចជាទឹក ប្រពន្ធ័លូទឹកស្អុយ ថាមពល ប្រេង ឬ ទំនាក់ទំនង ។

៣. "ឧបករណ៍ផ្ទុះ ឬ គ្រោះថ្នាក់ដល់ជីវិត" មានន័យថា:

(ក) អាវុធផ្ទុះ ឬ អាវុធដែលបង្កគ្រោះថ្នាក់ ឬ ឧបករណ៍ដែលរៀបចំធ្វើឡើង ឬ មានសមត្ថភាពបង្កអោយស្លាប់ អោយទទួលរងរបួសលើរាងកាយយ៉ាងខ្លាំង ឬ ធ្វើអោយមានការប៉ះពាល់ខូចខាតខ្លាំង ឬ
(ខ) អាវុធ ឬ ឧបករណ៍ដែលរៀបចំធ្វើឡើង ឬ មានលទ្ធភាពបណ្តាលអោយស្លាប់ ធ្វើអោយរងរបួសធ្ងន់ធ្ងរ ឬ ធ្វើអោយខូចខាតទ្រព្យសម្បត្តិធ្ងន់ធ្ងរតាមរយៈការបញ្ចេញ ការចែកចាយ ឬ ការប៉ះពាល់សារធាតុគីមីពុល ភ្នាក់ងារសរីរាង្គ ឬ ភ្នាក់ងារបំពុល ឬ សារធាតុដូចគ្នា ឬ ឧបករណ៍វិទ្យុសកម្ម ឬ ព្យុះសកម្ម ។

៤. "កងកំលាំងយោធារបស់រដ្ឋមួយ " មានន័យថាកងកំលាំងប្រដាប់អាវុធរបស់រដ្ឋមួយដែលបានរៀបចំ ហ្វឹកហ្វឺន
នឹងបំពាក់អាវុធតាមច្បាប់ខាងក្នុងស្រុករបស់ខ្លួនដើម្បីបំរើគោលបំណងសំខាន់មួយនៃការការពារជាតិ ឬ សន្តិសុខ និង បុគ្គលដែលធ្វើសកម្មភាពដើម្បីគាំទ្រកងកំលាំងប្រដាប់អាវុធទាំងនោះ ដែលស្ថិតនៅក្រោមការបញ្ជារបស់ពួកគេ ការគ្រប់គ្រង និង ការទទួលខុសត្រូវ ។

៥. "ទីកន្លែងនៃការប្រើប្រាស់ជាសាធារណៈ" មានន័យថារាល់ផ្នែកទាំងឡាយរបស់អាគារ ដី ផ្លូវថ្នល់ ផ្លូវទឹក ឬ ទីតាំងផ្សេងៗទៀតដែលអាចចូលបាន ឬ បើកចំហរចំពោះសមាជិកសាធារណៈ ទោះបីជា

ប្រចាំ ឬ មួងម្កាល ឬ មួយរយៈ និង រួមមានទីតាំងធ្វើពាណិជ្ជកម្ម ធ្វើជំនួញ វប្បធម៌ ប្រវត្តិសាស្ត្រ អប់រំ សាសនា រដ្ឋាភិបាល កន្លែងកំសាន្តសប្បាយ លំហែកាយ ឬ ទីតាំងដូចគ្នាដែលអាចចូលបាន ឬ បើកចំហរដល់សាធារណៈ ។

៦. "ប្រពន្ធ័ដឹកជញ្ជូនសាធារណៈ" មានន័យថារាល់ឧបករណ៍ គ្រឿងមធ្យោបាយដឹកនាំ និងឧបករណ៍ផ្សេងៗទៀតទោះបីជាកម្មសិទ្ធិឯកជន ឬ សាធារណៈដែលត្រូវប្រើប្រាស់ក្នុង ឬ សំរាប់សេវាដែលមានជាសាធារណៈសំរាប់ការដឹកជញ្ជូនមនុស្ស ឬ ទំនិញ ។

## មាត្រា ២

១. ជនណាមួយប្រព្រឹត្តបទល្មើសមួយដែលមានចែងក្នុងអត្ថន័យនៃអនុសញ្ញានេះប្រសិនបើជននោះដោយខុសនឹងច្បាប់ និង ដោយចេតនាបញ្ជូន ដាក់ បញ្ចេញ ឬ ដាក់អោយផ្ទុះនូវគ្រាប់ផ្ទុះ ឬ ឧបករណ៍ ដែលមានគ្រោះថ្នាក់ដល់ជីវិតផ្សេងៗទៀត ក្នុង ឬ ចូលទៅក្នុង ឬ ប្រឆាំងនឹងទីកន្លែងមួយដែលសំរាប់ ប្រើប្រាស់ជាសាធារណៈ រដ្ឋមួយ ឬ ឧបករណ៍រដ្ឋាភិបាល ឬ ប្រពន្ធ័ដឹកជញ្ជូនសាធារណៈ ឬ ឧបករណ៍ ហេដ្ឋារចនាសម្ព័ន្ធ:

(ក) ដោយចេតនាបណ្តាលអោយមានការស្លាប់បាត់បង់ជីវិត ឬ គ្រោះថ្នាក់ធ្ងន់ធ្ងរដល់រាងកាយ ឬ

(ខ) ដោតចេតនាបណ្តាលអោយមានការខូចខាតធ្ងន់ធ្ងរលើកន្លែងទាំងនោះ ឧបករណ៍ ឬ ប្រពន្ធ័ ដែលការបំផ្លាញទាំងនោះបណ្តាលអោយ ឬ នាំអោយមានការខាតបង់ផ្នែកសេដ្ឋកិច្ចធ្ងន់ធ្ងរ ។

២.ជនណាក៏ដោយក៏ប្រព្រឹត្តបទល្មើសមួយប្រសិនបើជននោះប៉ុនប៉ងប្រព្រឹត្តបទល្មើសដូចមានចែងក្នុងកថាខណ្ឌ ១ នៃមាត្រានេះ ។

៣.ជនណាក៏ដោយក៏ប្រព្រឹត្តបទល្មើសមួយប្រសិនបើជននោះ:

(ក) ចូលរួមជាអ្នកផ្សំគំនិតក្នុងបទល្មើសណាមួយដូចមានចែងក្នុងកថាខណ្ឌ ១ ឬ ២ នៃមាត្រានេះ ឬ

(ខ) រៀបចំ ដឹកនាំអ្នកផ្សេងៗទៀតដើម្បីប្រព្រឹត្តបទល្មើសដូចមានចែងក្នុងកថាខណ្ឌ ១ ឬ ២ នៃមាត្រានេះ ឬ

(គ) តាមមធ្យោបាយណាមួយជួយសំរួលដល់ការប្រព្រឹត្តបទល្មើសមួយ ឬ ច្រើនដូចមានចែងក្នុងកថាខណ្ឌ ១ ឬ ២ នៃមាត្រានេះដោយមនុស្សមួយក្រុមដែលធ្វើសកម្មភាពឡើងជាមួយនឹងគោលបំណង

ឯកភាពគ្នាមួយ ការជួយសំរួលទាំងនោះត្រូវអមដោយចេតនា ហើយអាចធ្វើឡើងដោយមានគោលដៅបង្កើនសកម្មភាព ឬ គោលបំណងព្រហ្មទណ្ឌជាទូទៅរបស់ក្រុម ឬ ធ្វើឡើងដោយដឹងនូវចេតនារបស់ក្រុមដើម្បីប្រព្រឹត្តបទល្មើសមួយ ឬ ច្រើនដែលពាក់ព័ន្ធ ។

## មាត្រា ៣

អនុសញ្ញានេះមិនត្រូវយកទៅអនុវត្តចំពោះបទល្មើសដែលប្រព្រឹត្តឡើងនៅក្នុងរដ្ឋមួយ ជនសង្ស័ និង ជនរងគ្រោះគឺជាសញ្ជាតិរបស់រដ្ឋនោះ ជនសង្ស័យត្រូវបានគេរកឃើញក្នុងដែនដីរបស់រដ្ឋនោះ ហើយមិនមានរដ្ឋផ្សេងទៀតមានមូលដ្ឋានណាមួយតាមមាត្រា ៦ កថាខណ្ឌ ១ ឬ កថាខណ្ឌ ២ នៃអនុសញ្ញានេះប្រើប្រាស់ដែនអំណាច លើកលែងតែ បញ្ញត្តិនៃមាត្រា ១០ ដល់ ១៥ ត្រូវប្រើប្រាស់ក្នុងករណីទាំងនោះតាមលក្ខណៈជាក់ស្តែង ។

## មាត្រា ៤

ភាគីរដ្ឋនីមួយត្រូវអនុម័តវិធានការដូចនេះតាមការចាំបាច់:

(ក) ដើម្បីកំណត់ថាជាបទល្មើសឧក្រិដ្ឋក្រោមច្បាប់ក្នុងស្រុករបស់ខ្លួននូវបទល្មើសដែលមានចែងក្នុងមាត្រា ២ នៃអនុសញ្ញានេះ

(ខ) កំណត់អោយបទល្មើសទាំងនេះអាចដាក់ទោសបានសមស្របអាស្រ័យទៅតាមភាពធ្ងន់ធ្ងរនៃបទល្មើស ។

## មាត្រា ៥

ភាគីរដ្ឋនីមួយៗត្រូវអនុម័តវិធានការចាំបាច់រួមទាំងច្បាប់ក្នុងស្រុកក្នុងករណីសមស្រប ដើម្បីកំណត់ថាជនល្មើសប្រព្រឹត្តអំពើក្នុងវិសាលភាពនៃអនុសញ្ញា ជាពិសេសក្នុងករណីធ្វើឡើងដោយចេតនា ឬ ដោយគិតគូរជាមុនដើម្បីបង្កអោយមានសភាពវិកវរក្នុងចំណោមសាធារណៈជនទូទៅ ឬ ក្នុងក្រុមមនុស្ស ឬ មនុស្សណាម្នាក់មិនត្រូវបានចាត់ទុកថាមានហេតុផលនោះទេ ក្នុងកាលទេសណាក៏ដោយ ទោះតាមរយៈនយោបាយទស្សនៈវិទ្យា មនោគមវិជ្ជា ពូជសាសន៍ សាសនា ឬ លក្ខណៈផ្សេងៗទៀតស្រដៀងគ្នា និង ត្រូវផ្តន្ទាទោសដោយកំរិត ទោសស្របទៅតាមសភាពធ្ងន់ធ្ងរ ។

មាត្រា ៦

១. ភាគីរដ្ឋនីមួយៗត្រូវចាត់វិធានការទាំងនេះទៅតាមការចាំបាច់ដើម្បីកំណត់ពីសមត្ថកិច្ចរបស់ខ្លួនលើបទល្មើសដែលមានចែងក្នុងមាត្រា ២ នៅពេលៈ

(ក) បទល្មើសប្រព្រឹត្តឡើងក្នុងដែនដីរបស់រដ្ឋនោះ ឬ

(ខ) បទល្មើសប្រព្រឹត្តឡើងលើនាវាដែលបង្ហោះទង់ជាតិរបស់រដ្ឋនោះ ឬ អាកាសយានដែលបានចុះបញ្ជីក្រោមច្បាប់របស់រដ្ឋនោះនៅពេលដែលបទល្មើសនោះបានប្រព្រឹត្តឡើង ឬ

(គ) បទល្មើសប្រព្រឹត្តឡើងដោយសញ្ជាតិរបស់រដ្ឋនោះ ។

២. ភាគីរដ្ឋមួយក៏អាចកំណត់ពីដែនសមត្ថកិច្ចរបស់ខ្លួនលើបទល្មើសទាំងនោះនៅពេលដែលៈ

(ក) បទល្មើសប្រព្រឹត្តឡើងប្រឆាំងនឹងសញ្ជាតិរបស់រដ្ឋនោះ ឬ

(ខ) បទល្មើសប្រព្រឹត្តឡើងប្រឆាំងនឹងរដ្ឋមួយ ឬ ឧបករណ៍រដ្ឋាភិបាលរបស់រដ្ឋនោះនៅក្រៅប្រទេសរួមទាំងស្ថានទូត ឬ ទីតាំងការទូត ឬ កុងសុលផ្សេងរបស់រដ្ឋនោះ ឬ

(គ) បទល្មើសប្រព្រឹត្តឡើងដោយជនដែលគ្មានរដ្ឋ តែមានទីស្នាក់អាស្រ័យរបស់ខ្លួននៅក្នុងដែនដីរបស់រដ្ឋនោះ ឬ

(ឃ) បទល្មើសប្រព្រឹត្តឡើងក្នុងគោលបំណងបង្ខិតបង្ខំរដ្ឋនោះអោយធ្វើ ឬ ដកថយពីការធ្វើអំពើទាំងឡាយនោះ ឬ

(ង) បទល្មើសប្រព្រឹត្តឡើងលើយានអវកាសដែលប្រតិបត្តិការដោយរដ្ឋាភិបាលរបស់រដ្ឋនោះ ។

៣. បន្ទាប់ពីការធ្វើសច្ចាប័ន ការទទួលយក ការឯកភាព និង ការដាក់ប្រើប្រាស់បន្ថែមលើអនុសញ្ញានេះ ភាគីរដ្ឋនីមួយៗត្រូវជូនដំណឹងដល់អគ្គលេខាធិការរបស់អង្គការសហប្រជាជាតិនូវដែនអំណាចដែលខ្លួនបានកំណត់ក្រោមច្បាប់ក្នុងស្រុករបស់ខ្លួនស្របតាមកថាខណ្ឌ ២ នៃមាត្រានេះ ។ ប្រសិនបើមានការផ្លាស់ប្តូរអ្វី ភាគី រដ្ឋដែលពាក់ព័ន្ធត្រូវជូនដំណឹងជាបន្ទាន់ដល់អគ្គលេខាធិការ ។

៤. ភាគីរដ្ឋនីមួយៗក៏ត្រូវចាត់វិធានការទាំងនេះតាមការចាំបាច់ដើម្បីកំណត់អំពីដែនសមត្ថកិច្ចរបស់ខ្លួនលើបទល្មើសដែលមានចែងក្នុងមាត្រា ២ ក្នុងករណីដែលជនល្មើសមានវត្តមានក្នុងដែនដីរបស់ខ្លួន ហើយខ្លួនមិនធ្វើបត្យាប័នជននោះទៅបណ្តាភាគីរដ្ឋផ្សេងៗទៀតដែលបានកំណត់ដែនសមត្ថកិច្ចរបស់ពួកគេស្របតាមកថាខណ្ឌ ១ ឬ ២ នៃមាត្រានេះ ។

៥. អនុសញ្ញានេះមិនរំលាយចោលរាល់ដែនសមត្ថកិច្ចទាំងឡាយណាដែលភាគីរដ្ឋបង្កើតឡើងស្របតាមច្បាប់ក្នុងស្រុករបស់ខ្លួននោះទេ ។

មាត្រា ៧

១. បន្ទាប់ពីបានទទួលពត៌មានថាជនណាម្នាក់ដែលបានប្រព្រឹត្តបទល្មើស ឬ ត្រូវបានចោទប្រកាន់ថាបានប្រព្រឹត្តបទល្មើសមួយដូចមានចែងក្នុងមាត្រា ២ មានវត្តមានក្នុងដែនដីរបស់ខ្លួន ភាគីរដ្ឋដែលពាក់ពន្ធ័ត្រូវចាត់វិធានការទាំងនោះតាមការចាំបាច់ក្រោមច្បាប់ក្នុងស្រុករបស់ខ្លួនដើម្បីស៊ើបអង្កេតអង្គហេតុដែលមាននៅក្នុងពត៌មាននោះ ។

២. នៅពេលដែលបំពេញតំរូវការគ្រប់គ្រាន់ក្នុងការទទួលបានដីកា ភាគីរដ្ឋដែលក្នុងដែនដីរបស់ខ្លួនមានវត្តមានជនល្មើស ឬ ជនជាប់ចោទត្រូវចាត់វិធានការសមស្របតាមច្បាប់ក្នុងស្រុករបស់ខ្លួនដើម្បីកំណត់អោយច្បាស់នូវវត្តមានរបស់ជននោះសំរាប់ការកាត់ទោស ឬ ការធ្វើបត្យាប័ន ។

៣. ជនទាំងឡាយណាដែលត្រូវបានគេចាត់វិធានការដូចក្នុងកថាខណ្ឌ ២ នៃមាត្រានេះត្រូវមានសិទ្ធិៈ

(ក) ទំនាក់ទំនងដោយមិនបង្អង់ជាមួយនឹងតំណាងដែលនៅជិតបំផុតរបស់រដ្ឋរបស់ជននោះ ឬ បើពុំនោះទេត្រូវបានទទួលការការពារសិទ្ធិរបស់ជននោះ ឬ ប្រសិនបើជននោះមិនមានប្រទេស គឺដោយរដ្ឋដែលជននោះស្នាក់នៅ ។

(ខ) ទទួលការសួរសុខទុក្ខដោយតំណាងរបស់រដ្ឋនោះ ។

(គ) ទទួលការជូនដំណឹងអំពីសិទ្ធិរបស់ជននោះតាមកថាខណ្ឌ (ក) និង (ខ)

៤. សិទ្ធិដែលមានចែងក្នុងកថាខណ្ឌ ៣ នៃមាត្រានេះត្រូវអនុវត្តដោយស្របទៅតាមច្បាប់ និងគោលការណ៍របស់រដ្ឋដែលដែនដីរបស់រដ្ឋនោះមានវត្តមានជនល្មើស ឬ ជនដែលជាប់ចោទក្នុង ករណីដែលបញ្ញត្តិ នៃច្បាប់នោះ និង គោលការណ៍ផ្តល់សុពលភាពពេញលេញទៅតាមគោលបំណងនៃការផ្តល់សិទ្ធិដែលមាន ចែងក្នុងកថាខណ្ឌ ៣ ។

៥. បញ្ញត្តិនៃកថាខណ្ឌ ៣ និង ៤ នៃមាត្រានេះមិនត្រូវរើសអើងចំពោះសិទ្ធិរបស់ភាគីរដ្ឋដែលទាមទារនូវដែនសមត្ថកិច្ចស្របតាមមាត្រា ៦ អនុកថាខណ្ឌ ១(គ) និង ២(គ) ដើម្បីអញ្ជើញគណកម្មាធិការអន្តរជាតិរបស់អង្គការកាកបាទក្រហមអោយទំនាក់ទំនង និង ចូលសួរសុខទុកជនល្មើសដែលជាប់ចោទនោះ ។

៦. ស្របតាមមាត្រានេះ នៅពេលដែលភាគីរដ្ឋមួយបានបង្ខាំងអ្នកណាម្នាក់ ខ្លួនត្រូវជូនដំណឹងជាបន្ទាន់ ដោយផ្ទាល់ ឬ តាមរយៈអគ្គលេខារបស់អង្គការសហប្រជាជាតិ ភាគីរដ្ឋដែលបានកំណត់ដែនសមត្ថកិច្ចស្របតាមមាត្រា ៦ កថាខណ្ឌ ១ និង ២ និង ប្រសិនបើខ្លួនគិតថាសមស្រប ភាគីរដ្ឋផ្សេងៗទៀតៗដែលពាក់ព័ន្ធ លើការដែលជននោះត្រូវឃុំខ្លួន និង ក្នុងស្ថានភាពដែលទាមទារអោយមានការឃុំខ្លួនជននោះ ។ រដ្ឋដែលធ្វើការស៊ើបអង្កេតដូចមានចែងក្នុងកថាខណ្ឌ ១ នៃមាត្រានេះត្រូវជូនដំណឹងភ្លាមដល់បណ្តាភាគីរដ្ឋដូចបានលើកឡើងខាងលើនូវការរកឃើញរបស់ខ្លួន និង ត្រូវបង្ហាញថាតើខ្លួនមានបំណងប្រើប្រាស់ដែនសមត្ថកិច្ចរបស់ខ្លួន ឬ អត់ ។

មាត្រា ៨

១. ភាគីរដ្ឋដែលមានវត្តមានរបស់ជនជាប់ចោទក្នុងដែនដីរបស់ខ្លួន ក្នុងករណីដែលអនុវត្តមាត្រា៦ ហើយប្រសិនបើខ្លួនមិនធ្វើបត្យាប័នជននោះ ត្រូវមានកាតព្វកិច្ច ដោយគ្មានករណីលើកលែងអ្វីទាំងអស់ ទោះជាជនល្មើសនោះប្រព្រឹត្ត ឬ មិនប្រព្រឹត្តក្នុងដែនដីរបស់ខ្លួន បញ្ជូនករណីនោះដោយមិនបង្អង់ទៅអាជ្ញាធរមានសមត្ថកិច្ចដើម្បីធ្វើការចោទប្រកាន់ តាមរយៈនិតិវិធីស្របតាមច្បាប់របស់រដ្ឋនោះ ។ អាជ្ញាធរទាំងនោះធ្វើសេចក្តីសំរេចរបស់ខ្លួនតាមវិធីដូចគ្នាដូចក្នុងករណីបទល្មើសផ្សេងៗទៀតដែលមានសភាពធ្ងន់ធ្ងរ តាមច្បាប់របស់រដ្ឋនោះ ។

២. ក្នុងករណីដែលភាគីរដ្ឋត្រូវបានទទួលការអនុញ្ញាតិពីច្បាប់ក្នុងស្រុករបស់ខ្លួនអោយធ្វើបត្យាប័ន ឬ បើពុំនោះទេបញ្ជូនជនជាតិរបស់ខ្លួនតាមលក្ខខណ្ឌដែលថាជននោះនឹងត្រូវបញ្ជូនទៅរដ្ឋនោះដើម្បីបំរើទោសដែលបានដាក់ដោយសារជាលទ្ធផលនៃសវនាការ ឬ ដំណើនិតិវិធីដែលនៃការធ្វើបត្យាប័ន និង ការបញ្ជូនជនជាតិរបស់ខ្លួន ហើយរដ្ឋនេះ និង រដ្ឋដែលស្នើសុំការធ្វើបត្យាប័នលើជននោះឯកភាពលើយោបល់នេះ និង លក្ខខណ្ឌដែលពួកគេគិតថាសមស្រប ការធ្វើបត្យាប័នក្រោមលក្ខណ្ឌទាំងនោះត្រូវគ្រប់គ្រាន់ដើម្បីអនុវត្តកាតព្វកិច្ចដែលមានចែងក្នុងកថាខណ្ឌ ១ នៃមាត្រានេះ ។

មាត្រា ៩

១. បទល្មើសដែលមានចែងក្នុងមាត្រា ២ ត្រូវយល់ថាមានការរួមបញ្ចូលថាជាបទល្មើសដែលអាចដែលអាចធ្វើបត្យាប័នបានក្នុងសន្ធិសញ្ញាបត្យាប័នណាក៏ដោយដែលមានរវាងភាគីរដ្ឋនានាមុនពេលចូលជា

ចរ មាននៃអនុសញ្ញានេះ ។ ភាគីរដ្ឋរួមបញ្ចូលបទល្មើសទាំងនេះថាជាបទល្មើសដែលអាចធ្វើបត្យាប័នបាន នៅគ្រប់សន្ធិសញ្ញាដែលត្រូវធ្វើឡើងក្រោយៗមទៀតរវាងពួកគេ ។

២. នៅពេលដែលភាគរដ្ឋដែលធ្វើបត្យាប័នដោយមានលក្ខណ្ឌតាមអត្ថិភាពនៃសន្ធិសញ្ញាមួយ ទទួលសំណើរស្នើរសុំការធ្វើបត្យាប័នពិភាគីរដ្ឋផ្សេងមួយទៀតដែលមិនមានសន្ធិសញ្ញាធ្វើបត្យាប័នជាមួយរដ្ឋដែលត្រូវគេស្នើសុំអាច តាមជំរើសរបស់ខ្លួន ចាត់ទុកអនុសញ្ញានេះជាមូលដ្ឋានច្បាប់សំរាប់ការធ្វើបត្យាប័នលើបទល្មើសដែលមានចែងក្នុងមាត្រា ២ ។ ការធ្វើបត្យាប័នត្រូវផ្អែកលើលក្ខណ្ឌផ្សេងដែលមានចែងក្នុងច្បាប់របស់រដ្ឋទទួលសំណើរ ។

៣. ភាគីរដ្ឋដែលមិនធ្វើបត្យាប័ដោយលក្ខខណ្ឌលើអត្ថិភាពនៃសន្ធិសញ្ញាត្រូវទទួលស្គាល់បទល្មើសដែលមានចែងក្នុងមាត្រា ២ ថាជាបទល្មើសដែលអាចធ្វើបត្យាប័នបានរវាងពួកផងខ្លួន អាស្រ័យទៅតាមលក្ខខណ្ឌដែលមានចែងក្នុងច្បាប់របស់រដ្ឋទទួលសំណើរ ។

៤. ប្រសិនបើចាំបាច់ បទល្មើសដែលមានចែងក្នុងមាត្រា ២ ក្នុងគោលបំណងនៃការការធ្វើបត្យាប័នរវាងភាគីត្រូវគិតថាដូចក្នុងករណីដែលបទល្មើសប្រព្រឹត្តឡើងមិនត្រឹមតែក្នុងកន្លែងណាមួយដែលបទល្មើសនោះកើតឡើងនោះទេ ក៏ប៉ុន្តែក្នុងដែនដីរបស់រដ្ឋដែលបានកំណត់ដែនសមត្ថកិច្ចស្របតាមមាត្រា ៦ កថាខណ្ឌ ១ និង ២ ។

៥. បញ្ញត្តិនៃសន្ធិសញ្ញាបត្យាប័នទាំងអស់ និង ការឯកភាពផ្សេងៗរវាងភាគីរដ្ឋទាក់ទងនឹងបទល្មើសដែលមានចែងក្នុងមាត្រា ២ ត្រូវយល់ថាអាចធ្វើការកែតំរូវបានរវាងភាគីរដ្ឋអាស្រ័យដោយភាពស្របគ្នាជាមួយនឹងអនុសញ្ញានេះ ។

មាត្រា ១០

១. ភាគីរដ្ឋត្រូវសំរបសំរួលជួយគ្នាអោយអស់ពីសមត្ថភាពទាក់ទងនឹងការស៊ើបអង្កេត ឬ ដំណើរការ និងនិតិវិធីធ្វើបត្យាប័នដែលមានលើបទល្មើសដូចមានចែងក្នុងមាត្រា ២ ដោយរួមបញ្ចូលទាំងការជួយក្នុងការទទួលបានភស្តុតាងផ្សេងតាមតំរូវការចាំបាច់របស់និតិវិធី ។

២. ភាគីរដ្ឋត្រូវអនុវត្តកាតព្វកិច្ចរបស់ខ្លួនតាមកថាខណ្ឌ ១ នៃមាត្រានេះដោយស្របតាមរាល់សន្ធិសញ្ញា ឬ ការឯកភាពផ្សេងៗលើការជួយគ្នាទៅវិញទៅមកផែកច្បាប់ដែលអាចមានរវាងពួកគេ ។ ក្នុង

ករណីមិនមានសន្ធិសញ្ញា ឬ ការរៀបចំទាំងនោះ ភាគីរដ្ឋត្រូវជួយគ្នាទៅវិញទៅមកស្របតាមច្បាប់ក្នុងស្រុករបស់ខ្លួន ។

មាត្រា ១១

ដើម្បីគោលបំណងនៃការធ្វើបត្យាប័ន ឬ ការជួយគ្នាទៅវិញទៅមកផ្នែកច្បាប់ មិនមានបទល្មើសមួយណាដែលចែងក្នុងមាត្រា ២ត្រូវចាត់ទុកថាជាបទល្មើសនយោបាយ ឬ ជាបទល្មើសដែលទាក់ទងនឹងបទល្មើសនយោបាយ ឬ ជាបទល្មើសដែលប្រព្រឹត្តឡើងដើម្បីហេតុផលនយោបាយនោះទេ ។ ជាមួយគ្នានេះដែរ សំណើរសុំការធ្វើបត្យាប័ន ឬ ការជួយគ្នាទៅវិញទៅមកផ្នែកច្បាប់ដែលផ្អែកលើបទល្មើសដូចនេះអាចមិនត្រូវបានបដិសេធដោយសារតែមូលហេតុមួយថា វាពាក់ពន្ធ័នឹងបទល្មើសនយោបាយមួយ ឬ បទល្មើសដែលពាក់ពន្ធ័នឹងបទល្មើសនយោបាយ ឬ បទល្មើសដែលមានចេតនានយោបាយ ។

មាត្រា ១២

មិនមានអ្វីនៅក្នុងអនុសញ្ញានេះដែលត្រូវបកស្រាយថាជាការដាក់បង្ខំកាតព្វកិច្ចដើម្បីអោយធ្វើបត្យាប័ន ឬ ការជួយគ្នាទៅវិញទៅមកផ្នែកច្បាប់ ប្រសិនបើរដ្ឋទទួលសំណើរមានភស្តុតាងគ្រប់គ្រាន់ជឿថាសំណើរសុំការធ្វើបត្យាប័នលើបទល្មើសដែលមានចែងក្នុងមាត្រា ២ ឬ ការជួយគ្នាទៅវិញទៅមកផ្នែកច្បាប់ទាក់ទងនឹងបទល្មើសដែលបានកំណត់ដើម្បីគោលបំណងនៃការកាត់ទោស ឬ ការដាក់ទោសជនណាម្នាក់ដោយពូជសាសន៍របស់ជននោះ សាសនា ជនជាតិ ដើមកំណើត ឬ យោបល់ផ្នែកនយោបាយ ឬ ការគោរពតាមសំណើរនោះនឹងបណ្តាលអោយមានការរើសអើងចំពោះជននោះដោយមូលហេតុផ្សេងៗ ។

មាត្រា ១៣

១. ជនណាដែលកំពុងជាប់ឃុំឃាំង ឬ កំពង់បំរើទោសក្នុងដែនដីរបស់ភាគីរដ្ឋមួយ ហើយដែត្រូវបានស្នើសុំដោយភាគីរដ្ឋមួយទៀតដើម្បីធ្វើការឆ្លើយបំភ្លឺផ្តល់ភស្តុតាង ការចង្អុលបង្ហាញ ឬ បើពុំនោះទេផ្តល់ជំនួយក្នុងការទទួលបានភស្តុតាងសំរាប់ការស៊ើបអង្កេត ឬ ការកាត់ទោសចំពោះបទល្មើសតាមអនុសញ្ញានេះអាចត្រូវផ្ទេរប្រសិនបើត្រូវនឹងលក្ខណ្ឌដូចខាងក្រោម :

(ក) ជននោះផ្តល់ការឯកភាពរបស់ខ្លួន និង

(ខ) អាជ្ញាធមិមានសមត្ថកិច្ចនៃរដ្ឋទាំងពីរឯកភាពអាស្រ័យតាមលក្ខណ្ឌដែលរដ្ឋទាំងនោះយល់ថាសមស្រប ។

២. ដើម្បីគោលបំណងនៃមាត្រានេះ

(ក) រដ្ឋដែលជននេះត្រូវផ្ទេរទៅត្រូវមានអំណាច និង កាតព្វកិច្ចដើម្បីរក្សាជននេះក្នុងការឃុំឃាំង លើកលែងតែមានការស្នើសុំ ឬ ការអនុញ្ញាតិដោយរដ្ឋដែលផ្ទេរជននោះ ។

(ខ) រដ្ឋដែលជននោះផ្ទេរទៅត្រូវបអនុវត្តដោយមិនបង្អង់នូវកាតព្វកិច្ចរបស់ខ្លួនដើម្បីបញ្ជូនត្រឡប់ជននោះទៅក្រោមការឃុំឃាំងរបស់រដ្ឋដែលជននោះបានផ្ទេរមកដូចបានឯកភាពគ្នាជាមុន ឬ បើពុំនោះទេ បានឯកភាពដោយអាជ្ញាធមិមានសមត្ថកិច្ចរបស់រដ្ឋទាំងពីរ ។

(គ) រដ្ឋដែលត្រូវបញ្ជូនជនផ្ទេរនោះទៅមិនត្រូវតំរូវអោយរដ្ឋផ្ទេរចាប់ផ្តើមដំណើរការធ្វើបត្យាប័នសំរាប់អោយជននោះត្រឡប់មកវិញនោះទេ ។

(ឃ) ជនដែលបានផ្ទេរត្រូវបានទទួលនូវការរាប់បញ្ចូលការបំរើទោសរួចហើយក្នុងរដ្ឋដែលផ្ទេរជននោះ និង រដ្ឋដែលទទួលខ្លួន ។

៣. លើលែងតែភាគីរដ្ឋដែលបានផ្ទេរជននោះមកស្រមតាមមាត្រានេះឯកភាពទោះជននោះជាសញ្ជាតិអ្វីក៏ដោយក៏មិនត្រូវទទួលការកាត់ទោស ឬ ឃុំឃាំង ឬ ត្រូវដាក់អោយស្ថិតនៅក្រោមបំរាមផ្សេងៗចំពោះសិទ្ធិសេរីភាពផ្ទាល់ខ្លួនក្នុងដែនដីរបស់រដ្ឋដែលជននោះត្រូវផ្ទេរទៅទាក់ទងនឹងអំពើ ឬ ការកាត់ទោសមុនពេលចេញដំណើររបស់ជននោះពីដែនដីដែលផ្ទេរជននោះ ។

## មាត្រា ១៤

ជនណាដែលជាប់ឃុំឃាំង ឬ ស្ថិតនៅក្រោមការចាត់វិធានការណាមួយ ឬ ការអនុវត្តនិតិវិធីណាមួយស្របតាមអនុសញ្ញានេះត្រូវទទួលបាននូវការធានា រួមទាំងការអនុវត្តនូវសិទ្ធិ និង ការធានាផ្សេងៗស្របតាមច្បាប់របស់រដ្ឋក្នុងដែនដីដែលជននោះវត្តមាន និង បញ្ញត្តិច្បាប់អន្តរជាតិផ្សេងៗទៀតស្តីអំពីសិទ្ធិមនុស្ស ។

## មាត្រា ១៥

ភាគីរដ្ឋត្រូវសហការណ៍ក្នុងការបង្ការទុបស្កាត់បទល្មើសដែលមានចែងក្នុងមាត្រា ២ ជាពិសេសៈ

(ក) ដោយការចាត់វិធានការដែលអាចអនុវត្តបាន ប្រសិនបើចាំបាច់រួមទាំងការកែប្រែច្បាប់ក្នុងស្រុករបស់ខ្លួនដើម្បីបង្កា និង ប្រឆាំងទល់នឹងការរៀបចំក្នុងដែនដីរបស់ខ្លួនសំរាប់ការប្រព្រឹត្តបទល្មើសទាំងនោះក្នុង និង ក្រៅដែនដីរបស់ខ្លួន រួមទាំងវិធានការហាមប្រាមក្នុងដែនដីរបស់ពួកគេនូវសកម្មភាពល្មើសច្បាប់របស់ជនទាំងនោះ ក្រុម និង អង្គការចាត់តាំងដែលជំរុញ ញុះញង់ រៀបចំ និង ផ្តល់ហិរញ្ញវត្ថុដោយចេតនា ឬ ពាក់ព័ន្ធក្នុងការប្រព្រឹត្តបទល្មើសដូចមានចែងក្នុងមាត្រា ២ ។

(ខ) ដោយការផ្លាស់ប្តូរពត៌មានជាក់ច្បាស់ស្របតាមច្បាប់ជាតិរបស់ខ្លួន និង សំរបសំរួលវិធានការរដ្ឋបាល និង វិធានការផ្សេងៗទៀតដែលយល់ថាសមស្របដើម្បីបង្កទប់ស្កាត់ការប្រព្រឹត្តបទល្មើសដូចមានចែងក្នុងមាត្រា ២ ។

(គ) ក្នុងករណីសមស្រប តាមរយៈការស្រាវជ្រាវ និង ការរីកចំរើនទាក់ទងនឹងវិធីសាស្ត្រនៃការតាមដានជាតិផ្ទុះ និង សារធាតុដែលបង្កគ្រោះថ្នាក់ផ្សេងៗទៀតដែលបណ្តាលអោយគ្រោះថ្នាក់ដល់ជីវិត ឬ មានការប៉ះពាល់ដល់រាងកាយ ការប្រឹក្សា លើការរីកចំរើននូវបទដ្ឋាននៃការធ្វើគ្រឿងផ្ទុះដើម្បីកំណត់អំពីប្រភពក្នុងការស៊ើបអង្កេតក្រោយពេលផ្ទុះ ការផ្លាស់ប្តូរពត៌មានលើវិធានការបង្កាទុបស្កាត់ កិច្ចសហប្រតិបត្តិការណ៍ និង ការផ្ទេរបច្ចេកវិទ្យា ឧបករណ៍ និង សំភារៈដែលពាក់ព័ន្ធ ។

## មាត្រា ១៦

ដោយស្របតាមច្បាប់របស់ខ្លួន ឬ និតិវិធីដែលអាចអនុវត្តបានភាគីរដ្ឋដែលកាត់ទោសជនល្មើសត្រូវបញ្ជូនលទ្ធផលចុងក្រោយនៃនិតិវិធីទៅអគ្គលេខាធិការនៃអង្គការសហប្រជា ជាតិ ដែលជាអ្នកបញ្ជូនពត៌មានបន្តទៅភាគីរដ្ឋផ្សេងៗទៀត ។

## មាត្រា ១៧

ភាគីរដ្ឋត្រូវអនុវត្តភារកិច្ចរបស់ខ្លួនតាមអនុសញ្ញានេះតាមវិធីសាស្ត្រដែលស្របទៅនឹងសមភាពនៃអធិបតេយ្យភាព និង បូរណភាពដែនដីរបស់រដ្ឋ និង ការមិនជ្រៀតជ្រែកកិច្ចការផ្ទៃក្នុងរបស់រដ្ឋផ្សេងៗទៀត ។

## មាត្រា ១៨

គ្មានអ្វីនៅក្នុងអនុសញ្ញានេះផ្តល់សិទ្ធិអោយភាគីរដ្ឋមួយអនុវត្តនូវដែនសមត្ថកិច្ចរបស់ខ្លួន និង តួនាទីដែលបានរក្សាសំរាប់អាជ្ញាធរមិរបស់ភាគីរដ្ឋផ្សេងដោយច្បាប់ក្នុងស្រុករបស់ខ្លួន ។

មាត្រា ១៩

១. គ្មានអ្វីនៅក្នុងអនុសញ្ញានេះត្រូវប៉ះពាល់ដល់សិទ្ធិផ្សេងៗ កាតព្វកិច្ច និង ការទទួលខុសត្រូវរបស់រដ្ឋ និង បុគ្គលក្រោមច្បាប់អន្តរជាតិ ជាពិសេសគោលបំណង និង គោលការណ៍របស់ធម្មនុញ្ញរបស់អង្គការសហប្រជាជាតិ និង ច្បាប់មនុស្សធម៌អន្តរជាតិ ។

២. សកម្មភាពរបស់កងកំលាំងប្រដាប់អាវុធក្នុងពេលសង្គ្រាម ដូចដែលខ្លឹមសារបានកំណត់ក្នុងច្បាប់មនុស្សធម៌អន្តរជាតិ ដែលគ្រប់គ្រងដោយច្បាប់នោះ តែមិនគ្រប់គ្រងដោយអនុសញ្ញានេះ និង សកម្មភាពដែលធ្វើឡើងដោយកងកំលាំងយោធារបស់រដ្ឋមួយក្នុងការអនុវត្តភារកិច្ចជាផ្លូវការដែលមានចែងក្នុងគោលការផ្សេងៗទៀតនៃច្បាប់អន្តរជាតិ តែមិនស្ថិតក្រោមអនុសញ្ញានេះ ។

មាត្រា ២០

១. រាល់ជម្លោះរវាងភាគីរដ្ឋពីរ ឬ ច្រើនទាក់ទងនឹងការបកស្រាយ ឬ ការអនុវត្តអនុសញ្ញានេះដែលមិនអាច ដោះស្រាយបានតាមការចចាក្នុងពេលមួយសមស្រប នៅពេលមានសំណើរពីភាគីណាមួយត្រូវបញ្ជូនដើម្បីធ្វើ ការវិនិច្ឆ័យ ។ ប្រសិនបើក្នុងរយៈពេល ៦ ខែពីការកាលបរិច្ឆេទនៃការដាក់ស្នើនោះ ភាគីនៅតែមិនអាចឯក ភាពលើការរៀបចំការកាត់សេចក្តី ភាគីណាក៏ដោយនៃភាគីទាំងពីរអាចបញ្ជូនជម្លោះនោះទៅតុលាការយុត្តិ ធម៌អន្តរជាតិ ដោយការដាក់ពាក្យស្របតាមលក្ខន្តិករបស់តុលាការ ។

២. នៅពេលចុះហត្ថលេខា ធ្វើសច្ចាប្រ័ន ទទួលយក ឬ ការឯកភាពលើអនុសញ្ញានេះ ឬ ការឯកភាពដាក់បន្ថែមអោយប្រើ ភាគីរដ្ឋនីមួយៗប្រកាសថាខ្លួនមិនស្ថិតនៅក្រោមកថាខណ្ឌ ១នៃមាត្រនេះ ។ ភាគីរដ្ឋផ្សេងៗទៀតមិនស្ថិតនៅក្រោមកថាខណ្ឌ ១ នោះទេប្រសិនបើខ្លួនធ្វើការជំទាស់ ។

៣. រដ្ឋណាដែលធ្វើការជំទាស់ស្របតាមកថាខណ្ឌ ២ នៃមាត្រានេះអាចដកការជំទាស់របស់ខ្លួនវិញនៅពេលណាមួយក៏បានតាមរយៈការជូនដំណឹងដល់អគ្គលេខាធិការនៃអង្គការសហប្រជាជាតិ ។

មាត្រា ២១

១. អនុសញ្ញានេះត្រូវបើកចំហរអោយចុះហត្ថលេខាដោយរដ្ឋទាំងអស់ចាប់ពីថ្ងៃទី ១២ ខែ មករា ១៩៩៨ រហូតដល់ ៣១ ធ្នូ ១៩៩៩ នៅទីស្នាក់ការរបស់អង្គការសហប្រជាជាតិនៅទីក្រុង ញូយ៉ក ។

២. អនុសញ្ញានេះត្រូវដាក់អោយធ្វើសច្ចាប្រ័ន ទទួលយក ឬ ឯកភាព ។ លិខិតតុបករណ៍នៃការធ្វើសច្ចាប្រ័ន ការទទួលយក ឬ ការឯកភាពត្រូវដាក់ដំកល់ជាមួយនឹងអគ្គលេខាធិការនៃអង្គការសហប្រជាជាតិ ។

៣. អនុសញ្ញានេះត្រូវបើកចំហរអោយមានការដាក់បន្ថែមប្រើប្រាស់ដោយរដ្ឋ ។ លិខិតតុបករណ៍អំពីការដាក់បន្ថែមអោយប្រើត្រូវដាក់ដំកល់ជាមួយនឹងអគ្គលេខាធិការនៃអង្គការសហប្រជាជាតិ ។

មាត្រា ២២

១. អនុសញ្ញានេះត្រូវចូលជាធរមានសាមសិបថ្ងៃបន្ទាប់ពីកាលបរិច្ឆេទនៃការដាក់ដំកល់លិខិតតុបករណ៍ទី ២២ នៃការធ្វើសច្ចាប្រ័ន ការទទួលយក ការឯកភាព ឬ ការដាក់អោយប្រើបន្ថែមជាមួយនឹង អគ្គលេខាធិការនៃ អង្គការសហប្រជាជាតិ ។

២. ចំពោះរដ្ឋនីមួយៗដែលធ្វើសច្ចាប្រ័ន ទទួលយក ឯកភាព ឬ ដាក់ប្រើប្រាស់បន្ថែមលើអនុសញ្ញានេះ បន្ទាប់ពីដាក់ដំកល់លិខិតតុបករណ៍ទី ២២ នៃការធ្វើសច្ចាប្រ័ន ការទទួលយក ការឯកភាព ឬ ការដាក់អោយប្រើបន្ថែម អនុសញ្ញាត្រូវចូលចាធរមានសាមសិបថ្ងៃបន្ទាប់ពីការដាក់ដំកល់ដោយរដ្ឋនោះនូវលិខិតតុបករណ៍នៃការធ្វើសច្ចាប្រ័ន ការទទួលយក ការឯកភាព ឬ ការដាក់ប្រេប្រាស់បន្ថែម ។

មាត្រា ២៣

១. ភាគីណាក៏ដោយអាចជំទាស់នឹងអនុសញ្ញានេះដោយការជូនដំណឹងជាលាយលក្ខណ៍អក្សរទៅអគ្គលេខានៃ អង្គការសហប្រជាជាតិ ។

២. ការប្តឹងជំទាស់ត្រូវចាត់ទុកថាបានការបន្ទាប់ពីរយៈពេលមួយឆ្នាំក្រោយពីអគ្គលេខាធិការនៃអង្គការសហប្រជាជាតិបានទទួលការជំទាស់នោះ ។

មាត្រា ២៤

ទំរង់ដើមនៃអនុសញ្ញានេះជាភាសា អារ៉ាប់ ចិន អង់គ្លេស បារាំង រុស្ស៊ី និង អេស្ប៉ាញមានតំលៃស្មើគ្នាត្រូវដាក់ដំកល់នៅអគ្គលេខាធិការនៃអង្គការសហប្រជាជាតិដែលត្រូវបញ្ជូនឯកសារចំលងទៅអោយរដ្ឋទាំងអស់ ។

ជាសក្ខីភាពនៃអនុសញ្ញានេះ តំណាងពេញសិទ្ធិដែលបានទទួលការចាត់តាំងពីរដ្ឋាភិបាលរបស់ខ្លួន បានចុះហត្ថលេខាលើអនុសញ្ញានេះ ហើយបានដាក់ចំហរដើម្បីចុះហត្ថលេខានៅទីស្នាក់ការរបស់អង្គការសហប្រជាជាតិ នៅទីក្រុង ញូយក ចាប់តាំងពីថ្ងៃទី ១២ ខែ មករា ១៩៩៨ នេះតទៅ ។

UNITED NATIONS

A

General Assembly

Distr. GENERAL

A/RES/52/164
9 January 1998

Fifty-second session
Agenda item 152

## RESOLUTION ADOPTED BY THE GENERAL ASSEMBLY

*[on the report of the Sixth Committee (A/52/653)]*

### 52/164. International Convention for the Suppression of Terrorist Bombings

*The General Assembly,*

*Recalling* its resolution 49/60 of 9 December 1994, by which it adopted the Declaration on Measures to Eliminate International Terrorism, and its resolution 51/210 of 17 December 1996,

*Having considered* the text of the draft convention for the suppression of terrorist bombings prepared by the Ad Hoc Committee established by General Assembly resolution 51/210 of 17 December 1996[1] and the Working Group of the Sixth Committee,[2]

1. *Adopts* the International Convention for the Suppression of Terrorist Bombings annexed to the present resolution, and decides to open it for signature at United Nations Headquarters in New York from 12 January 1998 until 31 December 1999;

2. *Urges* all States to sign and ratify, accept or approve or accede to the Convention.

*72nd plenary meeting*
*15 December 1997*

[1] See *Official Records of the General Assembly, Fifty-second Session, Supplement No. 37* (A/52/37).

[2] See A/C.6/52/L.3, annex I.

98-76117

ANNEX

International Convention for the Suppression of Terrorist Bombings

*The States Parties to this Convention,*

*Having in mind* the purposes and principles of the Charter of the United Nations concerning the maintenance of international peace and security and the promotion of good-neighbourliness and friendly relations and cooperation among States,

*Deeply concerned* about the worldwide escalation of acts of terrorism in all its forms and manifestations,

*Recalling* the Declaration on the Occasion of the Fiftieth Anniversary of the United Nations of 24 October 1995,[3]

*Recalling also* the Declaration on Measures to Eliminate International Terrorism, annexed to General Assembly resolution 49/60 of 9 December 1994, in which, *inter alia,* "the States Members of the United Nations solemnly reaffirm their unequivocal condemnation of all acts, methods and practices of terrorism as criminal and unjustifiable, wherever and by whomever committed, including those which jeopardize the friendly relations among States and peoples and threaten the territorial integrity and security of States"

*Noting* that the Declaration also encouraged States "to review urgently the scope of the existing international legal provisions on the prevention, repression and elimination of terrorism in all its forms and manifestations, with the aim of ensuring that there is a comprehensive legal framework covering all aspects of the matter",

*Recalling* General Assembly resolution 51/210 of 17 December 1996 and the Declaration to Supplement the 1994 Declaration on Measures to Eliminate International Terrorism annexed thereto,

*Noting* that terrorist attacks by means of explosives or other lethal devices have become increasingly widespread,

*Noting also* that existing multilateral legal provisions do not adequately address these attacks,

*Being convinced* of the urgent need to enhance international cooperation between States in devising and adopting effective and practical measures for the prevention of such acts of terrorism and for the prosecution and punishment of their perpetrators,

*Considering* that the occurrence of such acts is a matter of grave concern to the international community as a whole,

*Noting* that the activities of military forces of States are governed by rules of international law outside the framework of this Convention and that the exclusion of certain actions from the coverage of this Convention does not condone or make lawful otherwise unlawful acts, or preclude prosecution under other laws,

---

[3] See resolution 50/6.

*Have agreed* as follows:

*Article 1*

For the purposes of this Convention:

1. "State or government facility" includes any permanent or temporary facility or conveyance that is used or occupied by representatives of a State, members of Government, the legislature or the judiciary or by officials or employees of a State or any other public authority or entity or by employees or officials of an intergovernmental organization in connection with their official duties.

2. "Infrastructure facility" means any publicly or privately owned facility providing or distributing services for the benefit of the public, such as water, sewage, energy, fuel or communications.

3. "Explosive or other lethal device" means:

(*a*) An explosive or incendiary weapon or device that is designed, or has the capability, to cause death, serious bodily injury or substantial material damage; or

(*b*) A weapon or device that is designed, or has the capability, to cause death, serious bodily injury or substantial material damage through the release, dissemination or impact of toxic chemicals, biological agents or toxins or similar substances or radiation or radioactive material.

4. "Military forces of a State" means the armed forces of a State which are organized, trained and equipped under its internal law for the primary purpose of national defence or security and persons acting in support of those armed forces who are under their formal command, control and responsibility.

5. "Place of public use" means those parts of any building, land, street, waterway or other location that are accessible or open to members of the public, whether continuously, periodically or occasionally, and encompasses any commercial, business, cultural, historical, educational, religious, governmental, entertainment, recreational or similar place that is so accessible or open to the public.

6. "Public transportation system" means all facilities, conveyances and instrumentalities, whether publicly or privately owned, that are used in or for publicly available services for the transportation of persons or cargo.

*Article 2*

1. Any person commits an offence within the meaning of this Convention if that person unlawfully and intentionally delivers, places, discharges or detonates an explosive or other lethal device in, into or against a place of public use, a State or government facility, a public transportation system or an infrastructure facility:

(*a*) With the intent to cause death or serious bodily injury; or

(*b*) With the intent to cause extensive destruction of such a place, facility or system, where such destruction results in or is likely to result in major economic loss.

2. Any person also commits an offence if that person attempts to commit an offence as set forth in paragraph 1 of the present article.

3. Any person also commits an offence if that person:

(*a*) Participates as an accomplice in an offence as set forth in paragraph 1 or 2 of the present article; or

(*b*) Organizes or directs others to commit an offence as set forth in paragraph 1 or 2 of the present article; or

(*c*) In any other way contributes to the commission of one or more offences as set forth in paragraph 1 or 2 of the present article by a group of persons acting with a common purpose; such contribution shall be intentional and either be made with the aim of furthering the general criminal activity or purpose of the group or be made in the knowledge of the intention of the group to commit the offence or offences concerned.

*Article 3*

This Convention shall not apply where the offence is committed within a single State, the alleged offender and the victims are nationals of that State, the alleged offender is found in the territory of that State and no other State has a basis under article 6, paragraph 1 or paragraph 2, of this Convention to exercise jurisdiction, except that the provisions of articles 10 to 15 shall, as appropriate, apply in those cases.

*Article 4*

Each State Party shall adopt such measures as may be necessary:

(*a*) To establish as criminal offences under its domestic law the offences set forth in article 2 of this Convention;

(*b*) To make those offences punishable by appropriate penalties which take into account the grave nature of those offences.

*Article 5*

Each State Party shall adopt such measures as may be necessary, including, where appropriate, domestic legislation, to ensure that criminal acts within the scope of this Convention, in particular where they are intended or calculated to provoke a state of terror in the general public or in a group of persons or particular persons, are under no circumstances justifiable by considerations of a political, philosophical, ideological, racial, ethnic, religious or other similar nature and are punished by penalties consistent with their grave nature.

*Article 6*

1. Each State Party shall take such measures as may be necessary to establish its jurisdiction over the offences set forth in article 2 when:

(*a*) The offence is committed in the territory of that State; or

(*b*) The offence is committed on board a vessel flying the flag of that State or an aircraft which is registered under the laws of that State at the time the offence is committed; or

(*c*) The offence is committed by a national of that State.

2. A State Party may also establish its jurisdiction over any such offence when:

(*a*) The offence is committed against a national of that State; or

(*b*) The offence is committed against a State or government facility of that State abroad, including an embassy or other diplomatic or consular premises of that State; or

(*c*) The offence is committed by a stateless person who has his or her habitual residence in the territory of that State; or

(*d*) The offence is committed in an attempt to compel that State to do or abstain from doing any act; or

(*e*) The offence is committed on board an aircraft which is operated by the Government of that State.

3. Upon ratifying, accepting, approving or acceding to this Convention, each State Party shall notify the Secretary-General of the United Nations of the jurisdiction it has established under its domestic law in accordance with paragraph 2 of the present article. Should any change take place, the State Party concerned shall immediately notify the Secretary-General.

4. Each State Party shall likewise take such measures as may be necessary to establish its jurisdiction over the offences set forth in article 2 in cases where the alleged offender is present in its territory and it does not extradite that person to any of the States Parties which have established their jurisdiction in accordance with paragraph 1 or 2 of the present article.

5. This Convention does not exclude the exercise of any criminal jurisdiction established by a State Party in accordance with its domestic law.

*Article 7*

1. Upon receiving information that a person who has committed or who is alleged to have committed an offence as set forth in article 2 may be present in its territory, the State Party concerned shall take such measures as may be necessary under its domestic law to investigate the facts contained in the information.

2. Upon being satisfied that the circumstances so warrant, the State Party in whose territory the offender or alleged offender is present shall take the appropriate measures under its domestic law so as to ensure that person's presence for the purpose of prosecution or extradition.

3. Any person regarding whom the measures referred to in paragraph 2 of the present article are being taken shall be entitled to:

(*a*) Communicate without delay with the nearest appropriate representative of the State of which that person is a national or which is otherwise entitled to protect that person's rights or, if that person is a stateless person, the State in the territory of which that person habitually resides;

(*b*) Be visited by a representative of that State;

(*c*) Be informed of that person's rights under subparagraphs (*a*) and (*b*).

4. The rights referred to in paragraph 3 of the present article shall be exercised in conformity with the laws and regulations of the State in the territory of which the offender or alleged offender is present, subject to the provision that the said laws and regulations must enable full effect to be given to the purposes for which the rights accorded under paragraph 3 are intended.

5. The provisions of paragraphs 3 and 4 of the present article shall be without prejudice to the right of any State Party having a claim to jurisdiction in accordance with article 6, subparagraph 1 (*c*) or 2 (*c*), to invite the International Committee of the Red Cross to communicate with and visit the alleged offender.

6. When a State Party, pursuant to the present article, has taken a person into custody, it shall immediately notify, directly or through the Secretary-General of the United Nations, the States Parties which have established jurisdiction in accordance with article 6, paragraphs 1 and 2, and, if it considers it advisable, any other interested States Parties, of the fact that that person is in custody and of the circumstances which warrant that person's detention. The State which makes the investigation contemplated in paragraph 1 of the present article shall promptly inform the said States Parties of its findings and shall indicate whether it intends to exercise jurisdiction.

## *Article 8*

1. The State Party in the territory of which the alleged offender is present shall, in cases to which article 6 applies, if it does not extradite that person, be obliged, without exception whatsoever and whether or not the offence was committed in its territory, to submit the case without undue delay to its competent authorities for the purpose of prosecution, through proceedings in accordance with the laws of that State. Those authorities shall take their decision in the same manner as in the case of any other offence of a grave nature under the law of that State.

2. Whenever a State Party is permitted under its domestic law to extradite or otherwise surrender one of its nationals only upon the condition that the person will be returned to that State to serve the sentence imposed as a result of the trial or proceeding for which the extradition or surrender of the person was sought, and this State and the State seeking the extradition of the person agree with this option and other terms they may deem appropriate, such a conditional extradition or surrender shall be sufficient to discharge the obligation set forth in paragraph 1 of the present article.

## *Article 9*

1. The offences set forth in article 2 shall be deemed to be included as extraditable offences in any extradition treaty existing between any of the States Parties before the entry into force of this Convention. States Parties undertake to include such offences as extraditable offences in every extradition treaty to be subsequently concluded between them.

2. When a State Party which makes extradition conditional on the existence of a treaty receives a request for extradition from another State Party with which it has no extradition treaty, the requested State Party may, at its option, consider this Convention as a legal basis for extradition in respect of the offences set forth in article 2. Extradition shall be subject to the other conditions provided by the law of the requested State.

3. States Parties which do not make extradition conditional on the existence of a treaty shall recognize the offences set forth in article 2 as extraditable offences between themselves, subject to the conditions provided by the law of the requested State.

-បានឃើញព្រះរាជក្រមលេខ ០២ / នស / ៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី

-យោងតាមការងារចាំបាច់របស់រាជរដ្ឋាភិបាល

## សំ រេ ច

**ប្រការ ១ :** ត្រូវបានផ្ទេរសិទ្ធិជូនឯកឧត្ដម **ស ខេង** ឧបនាយករដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ជានាយករដ្ឋមន្ត្រីស្ដីទី នៃរាជរដ្ឋាភិបាលកម្ពុជា ជំនួសសម្ដេចនាយករដ្ឋមន្ត្រីដែលត្រូវអញ្ជើញទៅចូលរួមចូលរួមពិធីបើកសន្និសិទកំពូលពុទ្ធសាសនាពិភពលោកលើកទី៤ និងកិច្ចប្រជុំកំពូលលើកទី២ ស្ដីពីកិច្ចសហប្រតិបត្តិការសេដ្ឋកិច្ច កម្ពុជា ឡាវ-មីយ៉ាន់ម៉ា-ថៃ និងវៀតណាម (ACMECS) ដែលនឹងប្រព្រឹត្តទៅនៅទីក្រុងបាងកក ព្រះរាជាណាចក្រថៃ ចាប់ពីថ្ងៃទី ៣១ ខែ តុលា ឆ្នាំ ២០០៥ រហូតដល់សម្ដេចនាយករដ្ឋមន្ត្រីអញ្ជើញវិលនិវត្តន៍មកកាន់មាតុប្រទេសវិញ ។

**ប្រការ ២ :** រដ្ឋមន្ត្រីទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រី រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួង ស្ថាប័នរបស់រាជរដ្ឋាភិបាល ប្រតិភូរាជរដ្ឋាភិបាល អភិបាលខេត្ត-ក្រុង និងឯកឧត្ដម ស ខេង ត្រូវអនុវត្តសេចក្ដីសំរេចនេះអោយមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

*រាជធានីភ្នំពេញ ថ្ងៃទី [illegible] ខែ តុលា ឆ្នាំ ២០០៥*

នាយករដ្ឋមន្ត្រី

**ហ៊ុន សែន**

**កន្លែងទទួល :**

*-ក្រសួងព្រះបរមរាជវាំង*
*-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*
*-អគ្គលេខាធិការដ្ឋានរដ្ឋសភា*
*-ខុទ្ទកាល័យសម្ដេចនាយករដ្ឋមន្ត្រី*
*-ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី*
*-ដូចប្រការ ២*
*-ឯកសារ-កាលប្បវត្តិ*

# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

MINISTRY OF ECONOMY AND FINANCE

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

លេខ ៦៥៧ សហវ

## ប្រកាសអន្តរក្រសួង
## ស្តីពី
## ការអនុញ្ញាតឱ្យសេវាសុខាភិបាលអនុវត្ត ការពិនិត្យ និងព្យាបាលជំងឺដោយ យកកំរៃខ្លះពីអ្នកជំងឺ

៚*៚

### រដ្ឋមន្ត្រីក្រសួងសុខាភិបាល និងឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា ។
- បានឃើញព្រះរាជក្រមលេខ ៥/សរកម/០៧០៤/០០១ ចុះថ្ងៃទី ១៣-០៧-២០០៤ ដែលប្រកាសអោយប្រើច្បាប់រដ្ឋធម្មនុញ្ញបន្ថែមសំរាប់ធានានូវដំណើរការជាប្រក្រតីនៃស្ថាប័នជាតិ ។
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ចុះថ្ងៃទី ១៥-០៧-២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា ។
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០២ ចុះថ្ងៃទី ២៤-០១-៩៦ ប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសុខាភិបាល ។
- បានឃើញព្រះរាជក្រមលេខ នស/ រកម / ០១៩៦ / ១៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ៦៧ អនក្រ-បក ចុះថ្ងៃទី ២២-១០-៩៧ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងសុខាភិបាល ។
- បានឃើញអនុក្រឹត្យលេខ ០៤ អនក្រ.បក ចុះថ្ងៃទី ២០ ខែ មករា ឆ្នាំ២០០០ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ។
- អនុវត្តតាមសេចក្តីជូនដំណឹងលេខ ១២៩១ ស.ជ.ណ.អ.រ ចុះថ្ងៃទី ២២ ខែសីហា ឆ្នាំ១៩៩៥ របស់ទីស្តីការគណៈរដ្ឋមន្ត្រីស្តីពីការឯកភាពជាគោលការណ៍ ឱ្យមន្ទីរពេទ្យរដ្ឋ ថ្នាក់កណ្តាល ថ្នាក់ខេត្ត-ក្រុង និងថ្នាក់ស្រុក រៀបចំផ្នែកពិនិត្យ និង ព្យាបាលជំងឺយកកំរៃពីអ្នកជំងឺខ្លះ។ ។

# សម្រេច

**ប្រការ ១ :** ត្រូវបានអនុញ្ញាតឱ្យផ្នែកសេវាសុខាភិបាល រៀបចំការបង្កើតការពិនិត្យ និង ព្យាបាលជំងឺ យកកំរៃពីអ្នកជំងឺ តាមមន្ទីរពេទ្យថ្នាក់កណ្តាល មន្ទីរពេទ្យបង្អែកខេត្ត-ស្រុក និង មណ្ឌលសុខភាព ។

**ប្រការ ២ :** សេវាដូចមានចែងក្នុងប្រការ ១ ត្រូវអនុវត្តតាមគោលនយោបាយសុខាភិបាល ដោយត្រូវយកចិត្តទុកដាក់ថែទាំអ្នកជំងឺ គោរពសីលធម៌ វិជ្ជាជីវៈ ក្នុងស្មារតី មនុស្សធម៌ ទូលំទូលាយ រក្សាបាននូវគុណភាពសេវា និង មិនយកថ្លៃពីអ្នកជំងឺក្រីក្រ ។

**ប្រការ ៣ :** ការកំណត់កំរិតកំរៃដែលត្រូវយកពីអ្នកជំងឺ អាស្រ័យដោយគណៈកម្មការមួយដែលមានតំណាងក្រសួងសេដ្ឋកិច្ចហិរញ្ញវត្ថុ តំណាងក្រសួងសុខាភិបាល និង អង្គភាព. រៀបចំដោយរដ្ឋមន្ត្រីក្រសួងសុខាភិបាល សំរាប់អង្គភាពថ្នាក់កណ្តាល ។

ចំពោះអង្គភាពខេត្ត-ក្រុង ស្រុក និង មណ្ឌលសុខភាព អាស្រ័យដោយគណៈកម្មការមួយដែលមានតំណាងសហគមន៍ តំណាងមន្ទីរហិរញ្ញវត្ថុ និង ប្រធានសាម៉ីអង្គភាព រៀបចំដោយមន្ទីរសុខាភិបាលខេត្ត-ក្រុង រឺ គណៈកម្មការអភិវឌ្ឍន៍ស្រុក ឃុំ ។

**ប្រការ ៤ :** ថវិកាដែលប្រមូលបានពីអ្នកជំងឺ ត្រូវគ្រប់គ្រង និង ចាត់ចែងដូចខាងក្រោមនេះ :

- ៣៩% សំរាប់ជំនួយបង្កើនគុណភាពសេវាកម្ម
- ៦០% សំរាប់ចំណាយឧបត្ថម្ភមន្ត្រីរាជការ និយោជិត
- ១ % សំរាប់បង់ចូលថវិកាជាតិ ។

ដោយឡែកចំណូលផ្សេងៗទៀតក្រៅពីចំណូលខាងលើត្រូវបង់ចូលថវិការដ្ឋ ៧៥% និង ២៥% សំរាប់ជំនួយបង្កើនគុណភាពសេវាកម្ម ។

**ប្រការ ៥ :** ដើម្បីឱ្យមានតម្លាភាពក្នុងការប្រើប្រាស់ប្រាក់ចំណូលនេះ គណៈកម្មាការហិរញ្ញប្បទាននិងអង្គភាព ត្រូវធ្វើរបាយការណ៍ចំណូលចំណាយ ជូនក្រសួងសុខាភិបាល និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ អោយបានជាប្រចាំរៀងរាល់ ត្រីមាស និងប្រចាំឆ្នាំ ។

**ប្រការ ៦ :** បទបញ្ញត្តិទាំងឡាយណា ដែលផ្ទុយនឹងប្រកាសនេះ ត្រូវទុកជានិរាករណ៍ ។

**ប្រការ ៧** : អគ្គនាយករដ្ឋបាលហិរញ្ញវត្ថុ នាយកខុទ្ទកាល័យក្រសួងសុខាភិបាល អគ្គនាយកបច្ចេកទេស សុខាភិបាលប្រធានមន្ទីរសុខាភិបាលខេត្ត-ក្រុង ប្រធានមន្ទីរពេទ្យជាតិ មន្ទីរពេទ្យបង្អែក ប្រធានមណ្ឌលសុខភាព អង្គភាពពាក់ពន្ធ័ទាំងអស់ដែលស្ថិតក្រោមឱវាទក្រសួងសុខាភិបាល និង ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុមានភារៈកិច្ចទទួលបន្ទុកអនុវត្តប្រកាសនេះឱ្យមានប្រសិទ្ធិភាពចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

រាជធានីភ្នំពេញ, ថ្ងៃទី១១ ខែតុលា ឆ្នាំ ២០០៥

រដ្ឋមន្ត្រីក្រសួងសុខាភិបាល

រដ្ឋ. នុត សុខុម

ទេសរដ្ឋមន្ត្រី

រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

រដ្ឋមន្ត្រីស្តីទី

គង់ វិបុល

ចំលងជូន :

- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ទីស្តីការគណៈរដ្ឋមន្ត្រី
- គ្រប់ក្រសួង រដ្ឋលេខាធិការដ្ឋាន
- គ្រប់សាលាខេត្ត-ក្រុង

  " ដើម្បីជូនជ្រាប "
- ដូចប្រការ៧ " ដើម្បីអនុវត្ត "
- ឯកសារ និង កាលប្បវត្តិ

## ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

លេខ ៦៩៦ សហវ.ប្រក

រាជធានីភ្នំពេញ, ថ្ងៃទី ២០ ខែតុលា ឆ្នាំ ២០០៥

## ប្រកាស
## ស្តីពី
## ការកែសំរួលសមាសភាពគណៈកម្មការអន្តរក្រសួង ដើម្បីចុះពិនិត្យ និង វាយតំលៃ លើផលប៉ះពាល់ដល់សំណង់ផ្ទះសម្បែង ដីធ្លី ប្រជារាស្ត្រដោយសារ គំរោងការអភិវឌ្ឍន៍ ទេសចរណ៍ មេគង្គ

### ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខៈ នស/រកត/១១៩៨/៦៩ ចុះថ្ងៃទី ២៥ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី ដែលប្រកាសឱ្យប្រើដោយ ព្រះរាជក្រមលេខៈ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែកក្កដា ឆ្នាំ ១៩៩៤
- បានឃើញច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដែលប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខៈនស/រកម/០១៩៦/១៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦
- បានឃើញចំណារឯកភាពរបស់សម្តេចនាយករដ្ឋមន្ត្រី នៃ ព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ២០ ខែ កុម្ភៈ ឆ្នាំ ២០០៤
- ប្រកាសលេខ ១៥១ សហវ.ប្រក របស់ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ចុះថ្ងៃទី ២៨ ខែ ឧសភា ឆ្នាំ ២០០៤

## ស ំ រេ ច

**ប្រការ ១ :** កែសំរួលសមាសភាពគណៈកម្មការអន្តរក្រសួង ដើម្បីធ្វើការវាយតំលៃលើផលប៉ះពាល់សំណង់ផ្ទះសម្បែង ដីធ្លី និងទ្រព្យសម្បត្តិផ្សេងៗរបស់ប្រជារាស្ត្រក្នុងគំរោងការអភិវឌ្ឍន៍ ទេសចរណ៍ មេគង្គ ។

**ប្រការ ២ :** គណៈកម្មការអន្តរក្រសួងនេះ ត្រូវបានកែសំរួលសមាសភាពដូចខាងក្រោម :

| | | |
|---|---|---|
| ១. | ឯកឧត្តម **ញាណ ឡេង** អនុរដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | ប្រធាន |
| ២. | ឯកឧត្តម **ខង្សី ទិស្សុត** អគ្គលេខាធិការរង នៃ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | អនុប្រធាន |
| ៣. | ឯកឧត្តម **ស្តុត សំបូរ** អគ្គនាយក អគ្គនាយកដ្ឋានរដ្ឋបាល ក្រសួងសាធារណការ និងដឹកជញ្ជូន | សមាជិក |

៤. លោក និត ចន្ថា អគ្គនាយករងទេសចរណ៍ នៃ ក្រសួងទេសចរណ៍ សមាជិក

៥. លោក ហ៊ុយ ណារ៉ា អគ្គនាយករង នៃអគ្គនាយកដ្ឋានសំណង់ ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ សមាជិក

៦. លោក សេង ទារ៉ានី ប្រធាននាយកដ្ឋានរដ្ឋបាល នៃ រដ្ឋលេខាធិការអាកាសចរស៊ីវិល សមាជិក

៧. លោក រស់ បរម អនុប្រធាននាយកដ្ឋានវិនិយោគ និង សហប្រតិបត្តិការ នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ សមាជិក

៨. លោកបណ្ឌិត ឈន សុភាព ប្រធានអង្គភាពរៀបចំការតាំងទីលំនៅឡើងវិញ នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុសមាជិក

៩. លោក ឌូ ទារ៉ានី អនុប្រធានអង្គភាពរៀបចំការតាំងទីលំនៅឡើងវិញ នៃ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ សមាជិក

១០.លោក ឋាក់ ប៊ុណ្ណារិទ្ធ អនុប្រធានការិយាល័យធនាគារអភិវឌ្ឍន៍អាស៊ី នាយកដ្ឋានវិនិយោគ និងសហប្រតិបត្តិការ នៃក្រសួង សេដ្ឋកិច្ច និងហិរញ្ញវត្ថុ សមាជិក

១១.លោក ហ៊ីម បញ្ញាឧត្តម ប្រធានផ្នែករដ្ឋបាល និង ហិរញ្ញវត្ថុ នៃ អង្គភាពរៀបចំការតាំងទីលំនៅឡើងវិញ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ សមាជិក

១២.លោក ស៊ុន សុខនី ប្រធានផ្នែកគំរោង ADB និង WB នៃអង្គភាពរៀបចំការតាំងទិលំនៅឡើងវិញ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ សមាជិក

**ប្រការ ៣** : គណៈកម្មការអន្តរក្រសួង មានភារកិច្ចចុះទៅពិនិត្យដល់ទីកន្លែង ធ្វើស្ថិតិលើផលប៉ះពាល់ដល់សំណង់ផ្ទះសម្បែង ដីធ្លីរបស់ប្រជារាស្ត្រ រួចធ្វើការវាយតម្លៃអោយបានសមស្រប ដើម្បីមានមូលដ្ឋានដាក់ជូនរាជរដ្ឋាភិបាលពិនិត្យ និង សំរេចនូវថវិកាមួយចំនួនជាគោលនយោបាយជូនដល់ប្រជារាស្ត្រវិញ ។

**ប្រការ ៤** : គណៈកម្មការនេះ មានអង្គភាពរៀបចំការតាំងទីលំនៅឡើងវិញ នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ជាសេនាធិការផ្ទាល់ និង មានសិទ្ធិស្នើសុំបង្កើតក្រុមការងារមួយដែលមានសមាសភាពមន្ត្រីជំនាញពាក់ព័ន្ធ សំរាប់បំពេញការងារប្រចាំថ្ងៃ ។

**ប្រការ ៥** : ក្រសួងសាធារណការ និងដឹកជញ្ជូន, ក្រសួងរៀបចំដែនដីនគរូបនីយកម្មនិងសំណង់, ក្រសួងទេសចរណ៍, រដ្ឋលេខាធិការដ្ឋានអាសចរស៊ីវិល, នាយកដ្ឋានវិនិយោគ និងសហប្រតិបត្តិការ , នាយកដ្ឋានទ្រព្យរដ្ឋ នៃ ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ មានភារកិច្ចអនុវត្តប្រកាសនេះ ចាប់តាំងពីថ្ងៃចុះហត្ថលេខានេះតទៅ ។

ឧបនាយករដ្ឋមន្ត្រី

រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

គាត ឈន់

ចំលងជូន :

- ខុទ្ទកាល័យព្រះមហាក្សត្រ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ដូចប្រការ ៥
- ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

MINISTRY OF ECONOMY AND FINANCE

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
លេខ ០៥០ សហវ.ប្រក.ពន្ធ

# ប្រកាស
## ស្តីពី
## ការបែងចែកប្រាក់រង្វាន់នៃការប្រមូលពន្ធលើមធ្យោបាយដឹកជញ្ជូន និង យានជំនិះគ្រប់ប្រភេទសំរាប់ឆ្នាំ២០០៥

## ទេសរដ្ឋមន្ត្រី
## រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី១៥ ខែកក្កដា ឆ្នាំ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- បានឃើញក្រឹត្យលេខ ២៤/ក្រ ចុះថ្ងៃទី១៥ ខែកុម្ភៈ ឆ្នាំ១៩៩១ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតពន្ធលើមធ្យោបាយដឹកជញ្ជូននិងយានជំនិះគ្រប់ប្រភេទ
- បានឃើញព្រះរាជក្រមលេខ ជស/រកម/០១៩៨/០១ ចុះថ្ងៃទី០៩ ខែមករា ឆ្នាំ១៩៩៨ ដែលប្រកាសអោយប្រើច្បាប់ស្តីពីហិរញ្ញវត្ថុសំរាប់ការគ្រប់គ្រងឆ្នាំ១៩៩៨
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២០២/០២១ ចុះថ្ងៃទី ៣០ ខែធ្នូ ឆ្នាំ២០០២ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីហិរញ្ញវត្ថុសំរាប់ការគ្រប់គ្រងឆ្នាំ ២០០៣
- បានឃើញអនុក្រឹត្យលេខ ០៨/អនក្រ ចុះថ្ងៃទី២០ ខែឧសភា ឆ្នាំ១៩៩១ ស្តីពីការប្រមូលពន្ធលើមធ្យោបាយដឹកជញ្ជូននិងយានជំនិះគ្រប់ប្រភេទ
- បានឃើញប្រកាសលេខ ០០៤ ប្រក/សហវ/ពដ ចុះថ្ងៃទី ០៤ ខែមករា ឆ្នាំ២០០១ ស្តីពីការផ្តល់រង្វាន់ជូនអង្គភាពពន្ធដារ

ផ្លូវលេខ ៩២ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ កម្ពុជា
St.92, Sangkat Wat Phnom, Khan Daun Penh, Phnom Penh, CAMBODIA.
ទូរស័ព្ទ : ៨៥៥-២៣-៧២៤ ៦៦៤ ទូរសារ : ៨៥៥-២៣ ៤២៧ ៧៩៨
Phone : 855-23-724 664 Fax : 855-23-427 798

- បានឃើញប្រកាសលេខ ២៨៧ សហវ/ពជ ចុះថ្ងៃទី០៨ ខែឧសភា ឆ្នាំ២០០៣ ស្តីពីការបែងចែកប្រាក់រង្វាន់របស់អង្គភាពពន្ធដារ
- បានឃើញប្រកាសលេខ ២៧០ សហវ/ប្រក ចុះថ្ងៃទី ០៣ ខែ មិថុនា ឆ្នាំ២០០៥ ស្តីពីការប្រមូលពន្ធលើមធ្យោបាយដឹកជញ្ជូននិងយានជំនិះគ្រប់ប្រភេទ សំរាប់ឆ្នាំ២០០៥
- យោងតាមការងារចាំបាច់ក្នុងការប្រមូលពន្ធលើមធ្យោបាយដឹកជញ្ជូននិងយានជំនិះគ្រប់ប្រភេទសម្រាប់ឆ្នាំ២០០៥

## សំរេច

**ប្រការ ១ :** ចាប់ពីថ្ងៃទី ១៦ ខែ កញ្ញា ឆ្នាំ២០០៥តទៅ អង្គភាពពន្ធដារនឹងធ្វើការត្រួតពិនិត្យផាកពិន័យចំនួនមួយដងស្មើប្រាក់ពន្ធបន្ថែមលើប្រាក់ពន្ធដែលត្រូវបង់ចំពោះមធ្យោបាយដឹកជញ្ជូន និង យានជំនិះទាំងឡាយណាដែលមិនបានបង់ពន្ធសំរាប់ឆ្នាំ២០០៥ ដូចបានកំណត់ក្នុងប្រការ ១ នៃប្រកាសលេខ ២៧០ សហវ.ប្រក ចុះថ្ងៃទី០៣ ខែ មិថុនា ឆ្នាំ២០០៥ ។

ប្រាក់ពិន័យដែលទទួលបានមកអំពីការពិន័យលើមធ្យោបាយដឹកជញ្ជូននិងយានជំនិះគ្រប់ប្រភេទសំរាប់ឆ្នាំ២០០៥ ត្រូវបានអនុញ្ញាតឱ្យបែងចែកដូចតទៅ :

ក-ប្រាក់ពិន័យដែលទទួលបានក្នុងកិច្ចប្រតិបត្តិការត្រួតពិនិត្យ *(នៅទីចំណតនានា)* ដែលមានសហការរវាងមន្ត្រីពន្ធដារ និង មន្ត្រីមានសមត្ថកិច្ចដែលបានចូលរួម ត្រូវបានអនុញ្ញាតឱ្យបែងចែកដូចតទៅ :

១- ៥០% (ហាសិបភាគរយ) ត្រូវបង់ចូលថវិការដ្ឋ ។

២- ៥០% (ហាសិបភាគរយ) ត្រូវបានអនុញ្ញាតឱ្យបែងចែកជាប្រាក់រង្វាន់ដូចតទៅ :

- ១៥% (ដប់ប្រាំភាគរយ) បង់ចូលនាយកដ្ឋានពន្ធដារ
- ៣៥%(សាមសិបប្រាំភាគរយ)សំរាប់បែងចែកដូចខាងក្រោម :
  + ៦០% នៃប្រាក់រង្វាន់ សំរាប់ចែកជូនសមាជិកនៃក្រុមប្រតិបត្តិការត្រួតពិនិត្យ ។
  + ២០% នៃប្រាក់រង្វាន់ សំរាប់បេឡាសមូហភាពរបស់សាខាពន្ធដារខេត្ត-ក្រុង ។
  + ១០% នៃប្រាក់រង្វាន់ សំរាប់បេឡាសមូហភាពរបស់សាលាខេត្ត-ក្រុង ។
  + ១០% នៃប្រាក់រង្វាន់ សំរាប់បេឡាសមូហភាពរបស់សាលាខ័ណ្ឌ-ស្រុក ។

ខ-ប្រាក់ពិន័យដែលទទួលបានក្នុងកិច្ចប្រតិបត្តិការត្រួតពិនិត្យ*(នៅក្នុង ភូមិ ឃុំ-សង្កាត់)*ដែលមានសហការរវាងមន្ត្រីពន្ធដារ នគរបាលឃុំ-សង្កាត់ ក្រុមប្រឹក្សាឃុំ-សង្កាត់ និងមន្ត្រីមានសមត្ថកិច្ចផ្សេងទៀតដែលបានចូលរួម ត្រូវបានអនុញ្ញាតឱ្យបែងចែកដូចតទៅ :

១- ៥០% (ហាសិបភាគរយ) ត្រូវបង់ចូលថវិការដ្ឋ ។

២- ៥០% (ហាសិបភាគរយ) ត្រូវបានអនុញ្ញាតឱ្យបែងចែកជាប្រាក់រង្វាន់ដូចតទៅ :

- ១៥% (ដប់ប្រាំភាគរយ) បង់ចូលនាយកដ្ឋានពន្ធដារ
- ៣៥%(សាមសិបប្រាំភាគរយ)សំរាប់បែងចែកដូចខាងក្រោម :
  + ៥០% នៃប្រាក់រង្វាន់ សំរាប់ចែកជូនសមាជិកនៃក្រុមប្រតិបត្តិការត្រួតពិនិត្យ ។
  + ២០% នៃប្រាក់រង្វាន់ សំរាប់បេឡាសមូហភាពរបស់សាខាពន្ធដារខេត្ត-ក្រុង ។
  + ១០% នៃប្រាក់រង្វាន់ សំរាប់បេឡាសមូហភាពរបស់សាលាខេត្ត-ក្រុង ។
  + ១០% នៃប្រាក់រង្វាន់ សំរាប់បេឡាសមូហភាពរបស់សាលាខ័ណ្ឌ-ស្រុក ។
  + ១០% នៃប្រាក់រង្វាន់ សំរាប់បេឡាសមូហភាពរបស់ក្រុមប្រឹក្សាឃុំ-សង្កាត់ ។

**ប្រការ ២ :** អនុញ្ញាតឱ្យសាខាពន្ធដារខេត្ត-ក្រុងនីមួយៗ ដកប្រាក់រង្វាន់ពីការផាកពិន័យពន្ធលើមធ្យោបាយដឹកជញ្ជូន និង យានជំនិះគ្រប់ប្រភេទសំរាប់ឆ្នាំ២០០៥នេះភ្លាមសំរាប់បែងចែកជូនសមាជិកក្រុមត្រួតពិនិត្យនិងអង្គភាព តាមសមាមាត្រដូចបានចែងក្នុងប្រការ១ខាងលើ ហើយត្រូវធ្វើរបាយការណ៍បូកសរុបពីស្ថានភាពចំណូល និង ចំណាយបេឡាប្រាក់រង្វាន់ជូននាយកដ្ឋានពន្ធដារ ដើម្បីពិនិត្យ និង សំរេចទូទាត់ជាក្រោយ ។

**ប្រការ ៣ :** ប្រកាសនេះ មានប្រសិទ្ធិភាពអនុវត្តចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ២១ ខែ តុលា ឆ្នាំ២០០៥

**គាត ឈន់**

**កន្លែងទទួល:**

- ទីស្តីការគណៈរដ្ឋមន្ត្រី "ដើម្បីជ្រាបជារបាយការណ៍"
- គ្រប់ក្រសួង-ស្ថាប័នកណ្តាល
- គ្រប់សាលាខេត្ត-ក្រុង

  "ដើម្បីជូនជ្រាបជាពត៌មាន"
- គ្រប់អង្គភាពក្រោមឱវាទក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

  "ដើម្បីមុខការ"
- គ្រប់សាខាពន្ធដារខេត្ត-ក្រុង "ដើម្បីអនុវត្ត"
- ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

លេខ......៦៩៦......សហវ.ប្រក

រាជធានីភ្នំពេញ,ថ្ងៃទី ២៤ ខែ តុលា ឆ្នាំ ២០០៥

# ប្រកាស
## ស្តីពី
## ការបង្កើតគណៈកម្មការបញ្ជីសារពើភ័ណ្ឌទ្រព្យសម្បត្តិរដ្ឋ ប្រចាំក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

## ទេសរដ្ឋមន្ត្រី
## រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស.រកត/០៧០៤/០០១ ចុះថ្ងៃទី១៣ ខែកក្កដា ឆ្នាំ២០០៤ ដែលប្រកាសឱ្យប្រើច្បាប់ធម្មនុញ្ញបន្ថែមសំដៅធានាដំណើរការជាប្រក្រតី នៃស្ថាប័នជាតិ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី១៥ ខែកក្កដា ឆ្នាំ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃ ព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២នស.៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ ១៩៩៤ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃទីស្តីការគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខនស/រកម/០៨០១/០៤ចុះថ្ងៃទី៣០ ខែសីហា ឆ្នាំ២០០១ ដែលប្រកាសឱ្យប្រើច្បាប់ភូមិបាល
- បានឃើញអនុក្រឹត្យលេខ០៤ អនក្រ.បក ចុះថ្ងៃទី ២០ ខែមករា ឆ្នាំ ២០០០ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ៧៨ អនក្រ.បក ចុះថ្ងៃទី ១៨ ខែវិច្ឆិកា ឆ្នាំ ២០០៤ ស្តីពីការបំពេញបន្ថែម និងកែសំរួលនាយកដ្ឋានមួយចំនួន នៃក្រសួង សេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញបទបញ្ជាលេខ ៣០ បប ចុះថ្ងៃទី ២៥ ខែធ្នូ ឆ្នាំ ១៩៩៧ របស់រាជរដ្ឋាភិបាល ស្តីពីការគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋ
- បានឃើញសារាចរណែនាំលេខ០១៦ សរ.សហវ ចុះថ្ងៃទី ១៩ ខែវិច្ឆិកា ឆ្នាំ ១៩៩៩ ស្តីពីថែរក្សាទ្រព្យសម្បត្តិរដ្ឋ និង ចំណារសម្តេចនាយករដ្ឋមន្ត្រី ចុះថ្ងៃទី ២២ ខែ វិច្ឆិកា ឆ្នាំ ១៩៩៩
- បានឃើញបទបញ្ជាលេខ ០២ បប ចុះថ្ងៃទី ១៣ ខែមិថុនា ឆ្នាំ ២០០៥ របស់រាជរដ្ឋាភិបាល
- បានឃើញចំណាររបស់ឯកឧត្តមទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ចុះថ្ងៃទី ១៦ ខែ មិថុនា ឆ្នាំ ២០០៤
- យោងការផ្លាស់ប្តូរភារកិច្ចមន្ត្រី ចំនួន០២រូប មន្ត្រីចូលនិវត្តន៍ចំនួន ០២រូប នៃប្រកាសលេខ ៩១០ សហវ ចុះថ្ងៃទី ០៥ ខែ ធ្នូ ឆ្នាំ ២០០១ និងបំពេញបន្ថែមមន្ត្រីជាសមាជិកគណៈកម្មការ ចំនួន ០២រូប
- យោងការងារចាំបាច់របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

## សំរេច

**ប្រការ១** : បង្កើតគណៈកម្មការបញ្ជីសារពើភ័ណ្ឌទ្រព្យសម្បត្តិរដ្ឋប្រចាំក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ដែលមានសមាសភាពដូចខាងក្រោម :

| | | |
|---|---|---|
| ១-ឯកឧត្តម ញាណ ឡេង | អនុរដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ | ប្រធាន |
| ២-លោក ឃុត សាខន | ប្រធាននាយកដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុ | អនុប្រធាន |
| ៣- លោក នេត មុន្នី | ប្រធាននាយកដ្ឋានទ្រព្យសម្បត្តិរដ្ឋ | អនុប្រធាន |
| ៤- លោក វង្ស ជាវ | ប្រធានការិយាល័យនីតិកម្មហិរញ្ញវត្ថុ នៃនាយកដ្ឋាននីតិកម្ម | សមាជិកអចិន្ត្រៃយ៍ |
| ៥- លោក លីវ ប៊ុនហៃ | ប្រធាននាយកដ្ឋានហិរញ្ញវត្ថុមូលដ្ឋាន | សមាជិក |
| ៦- លោក ឡាយ ឫទ្ធី | នាយករងទីចាត់ការគយ និង រដ្ឋាករ | សមាជិក |
| ៧- លោក ម៉ី រិន | អនុប្រធានរតនាគារជាតិ | សមាជិក |
| ៨- លោក វង្ស វុំដាវុឌ្ឍ | អនុប្រធាននាយកដ្ឋានលទ្ធកម្មសាធារណៈ | សមាជិក |
| ៩- លោក ចាន់ ស៊ុ | អនុប្រធាននាយកដ្ឋានពន្ធដារ | សមាជិក |
| ១០- លោក គុយ សារុធ | អនុប្រធាននាយកដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុ | សមាជិក |
| ១១-លោក មាស ចាន់ដេត | ប្រធានការិយាល័យគណនេយ្យនៃនាយកដ្ឋានរដ្ឋបាលនិងហិរញ្ញវត្ថុ | សមាជិក |
| ១២-លោក ហែម ស៊ីវន | ប្រធានការិយាល័យសារពើភ័ណ្ឌ នៃនាយកដ្ឋាទ្រព្យសម្បត្តិរដ្ឋ | សមាជិក |
| ១៣-លោក ម៉ុក ស៊ីជា | ប្រធានការិយាល័យត្រួតពិនិត្យ នៃនាយកដ្ឋានបុគ្គលិក | សមាជិក |
| ១៤-លោក ម៉ែន ណារុន | អនុប្រធានការិយាល័យសារពើភ័ណ្ឌ នៃនាយកដ្ឋានទ្រព្យសម្បត្តិរដ្ឋ | សមាជិក |
| ១៥- លោក ហេង សុខ័ណ្ឌ | មន្ត្រីនាយកដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុ | សមាជិក |
| ១៦- លោក ហ៊ុន ពិសិដ្ឋ | មន្ត្រីនាយកដ្ឋាននីតិកម្ម | លេខាធិការ និងជាការីកុំព្យូទ័រ |

**ប្រការ២** : គណៈកម្មការនេះមានភារកិច្ច :

- ត្រួតពិនិត្យ ផ្ទៀងផ្ទាត់ប្រចាំឆ្នាំនូវបញ្ជីសារពើភ័ណ្ឌទ្រព្យសម្បត្តិរដ្ឋ របស់អង្គភាពនៅថ្នាក់កណ្តាលចំណុះទីស្តីការក្រសួង និងមន្ទីរ-អង្គភាពជំនាញនៅតាមខេត្ត-ក្រុង ក្រោមឱវាទក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ដែលគ្រប់គ្រង និងប្រើប្រាស់ទ្រព្យសម្បត្តិរដ្ឋ ទោះបីធ្វើអាជីវកម្ម ឬ ប្រើប្រាស់ជាផលប្រយោជន៍រួមក៏ដោយព្រមទាំងកត់ត្រាឱ្យបានច្បាស់លាស់អំពីចំនួនកើន និង ចំនួនថយ ដោយប្រការផ្សេងៗដូចជា ដីធ្លី អគារ សម្ភារៈបរិក្ខារ....ដែលអាដ្ឋាធរដែនដី អង្គការអន្តរជាតិនានា សប្បុរសជនជាតិ និង អន្តរជាតិប្រគល់ឱ្យកន្លងមក លទ្ធផលនៃការប្រើប្រាស់ឥណទានសំរាប់ទិញដី ការកសាងថ្មី ជួសជុលអគារ សម្ភារៈបរិក្ខារ បច្ចេកទេសឧស្សាហកម្ម ការប្រើប្រាស់ឥណទានជំពូក ១១ កឋាខ័ណ្ឌ២ និង ការប្រើប្រាស់ប្រាក់រង្វាន់ ។ល។ ដើម្បីកត់ត្រាចូលក្នុងបញ្ជីសារពើភ័ណ្ឌជាទ្រព្យសម្បត្តិរដ្ឋ ។

- រាយការណ៍ជូនឯកឧត្តមទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ស្តីពីលទ្ធផលការត្រួតពិនិត្យផ្ទៀងផ្ទាត់ធ្វើបញ្ជីសារពើភ័ណ្ឌទ្រព្យសម្បត្តិរដ្ឋ អំពីចំនួនកើន និង ចំនួនថយទ្រព្យសម្បត្តិរដ្ឋ របស់អង្គភាពនៅថ្នាក់កណ្តាលចំណុះទីស្តីការក្រសួង និង មន្ទីរ-អង្គភាព ជំនាញនៅតាមខេត្ត-ក្រុង ព្រមទាំងលើកសំណើជូនឯកឧត្តមទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ដើម្បីពិនិត្យ និង សំរេច :

+ អំពីករណីដីធ្លី ដែលទុកចោលទំនេរ និង ធ្វើការបែងចែកដីជូនអង្គភាពជំនាញហិរញ្ញវត្ថុ ខេត្ត-ក្រុង ដែលគ្មានទីតាំងរដ្ឋបាល ដើម្បីជៀសវាងប្រការចំណាយឥណទានរបស់ក្រសួងក្នុងការទិញដីថ្មីឡើយ ។

+ អគារ យានយន្ត គ្រឿងចក្រ និងសម្ភារៈ សង្ហារឹម ដែលអស់តម្លៃក្នុងការប្រើប្រាស់ត្រូវស្នើសុំគោលការណ៍ជំរះចេញពីបញ្ជីសារពើភ័ណ្ឌទ្រព្យសម្បត្តិរដ្ឋ ។

- ក្នុងករណីចាំបាច់ ឬ មានវិវាទកម្មផ្សេងៗ គណៈកម្មការនេះត្រូវធ្វើអង្កេតវាយតម្លៃទ្រព្យសម្បត្តិរដ្ឋ គ្រប់អង្គភាពនៅថ្នាក់ កណ្តាលចំណុះទីស្តីការក្រសួង និង មន្ទីរ-អង្គភាពជំនាញនៅតាមខេត្ត-ក្រុង ជាបន្ទាន់ដោយមិនបាច់ជូនដំណឹងជាមុនឡើយ ដើម្បីទប់ស្កាត់រាល់បាតុភាពរំលោភបំពារបំពានយកទ្រព្យសម្បត្តិរដ្ឋ ។

**ប្រការ៣** : រាល់លិខិតបទដ្ឋានទាំងឡាយណា ដែលផ្ទុយនិងប្រកាសនេះត្រូវចាត់ទុកជានិរាករណ៍ ។

**ប្រការ៤** : ឯកឧត្តមអគ្គលេខាធិការ នាយកខុទ្ទកាល័យ នាយកដ្ឋានបុគ្គលិក នាយកដ្ឋានរដ្ឋបាល និង ហិរញ្ញវត្ថុ នាយកដ្ឋានទ្រព្យសម្បត្តិរដ្ឋ នាយកដ្ឋាននីតិកម្ម នាយកដ្ឋានហិរញ្ញវត្ថុមូលដ្ឋាន ទីចាត់ការគយ និង រដ្ឋាករ រតនាគារជាតិ នាយកដ្ឋានពន្ធដារ មន្ទីរសេដ្ឋកិច្ច និង ហិរញ្ញវត្ថុគ្រប់ខេត្ត-ក្រុង អង្គភាពពាក់ព័ន្ធ ព្រមទាំងអស់លោកដូចមានចែងក្នុងប្រការ១ ត្រូវទទួលបន្ទុកអនុវត្តតាមប្រកាស នេះឱ្យមានប្រសិទ្ធិភាពខ្ពស់ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

ទេសរដ្ឋមន្ត្រី
រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

គាត ឈន់

ចំលងជូន :
- ទីស្តីការគណៈរដ្ឋមន្ត្រី
- គ្រប់សាលាខេត្ត-ក្រុង
“ដើម្បីជូនជ្រាប”
- គ្រប់នាយកដ្ឋាន និងអង្គភាពចំណុះទីស្តីការក្រសួង
- ដូចប្រការ៤
“ដើម្បីអនុវត្ត”
- ឯកសារ - កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
**Kingdom of Cambodia**
Nation Religion King

**ក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល**
**Ministry of Industry, Mines and Energy**
N°៧៧១ ឧស៥.កឧ.ប្រក.

រាជធានីភ្នំពេញ, ថ្ងៃទី ១៧ ខែ តុលា ឆ្នាំ ២០០៥

# ប្រកាស

## រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/ រកត / ០៧០៤/ ១២៤ ចុះថ្ងៃទី១៥ ខែកក្កដា ឆ្នាំ២០០៤ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/ ០១៩៦/ ០៥ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការបង្កើត ក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល
- បានឃើញអនុក្រឹត្យលេខ ៣៥ អនក្រ.បក ចុះថ្ងៃទី២៦ ខែមេសា ឆ្នាំ១៩៩៨ ស្ដីពីការរៀបចំ និងការប្រព្រឹត្តិទៅរបស់ក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល
- បានឃើញលិខិតលេខ ៣១៧៧/០៥ គ.វ.ក ចុះថ្ងៃទី១៥.០៩.២០០៥ របស់ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
- យោងពាក្យស្នើរបស់ក្រុមហ៊ុន វ៉ាយថិច ហ្គាមេន ( ខេមបូឌា) ចុះថ្ងៃទី២២.០៩.២០០៥

# សំរេច

ប្រការ១: អនុញ្ញាតឱ្យក្រុមហ៊ុន វ៉ាយថិច ហ្គាមេន ( ខេមបូឌា)(WHITEX GARMENTS (CAMBODIA) CO., LTD.) តំណាងដោយ លោកស្រី LEE LI HEONG សញ្ជាតិម៉ាឡេស៊ី អាយុ៤៤ឆ្នាំ កាន់លិខិតឆ្លងដែនលេខ A10646501 ចុះថ្ងៃទី០២.០៨.២០០១ បង្កើតរោងចក្រ "កាត់ដេរសម្លៀកបំពាក់" ដែលមានឈ្មោះថា " វ៉ាយថិច ហ្គាមេន (ខេមបូឌា) ( WHITEX GARMENTS (CAMBODIA) )" មានទីតាំងស្ថិតនៅភូមិត្រពាំងថ្នឹង សង្កាត់ចោមចៅ ខណ្ឌដង្កោ រាជធានីភ្នំពេញ ។

៤៥ មហាវិថីព្រះនរោត្តម ខ័ណ្ឌដូនពេញ ភ្នំពេញ ទូរស័ព្ទ : (៨៥៥) ២៣.២១១១៤១ , ទូរសារ : ៨៥៥.២៣.៤២៨២៦៣
45 Preah Norodom Boulevard, Khan Daun Penh, Phnom Penh, Phone : 855.23.211141 , Fax : 855.23.428263

ប្រការ២: ក្នុងកិច្ចដំណើរការ ក្រុមហ៊ុនត្រូវរៀបចំរោងចក្រទៅតាមប្លង់ ដែលបានតំកល់ទុកនៅក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល ។

ប្រការ៣: រោងចក្រនេះ ត្រូវបានអនុញ្ញាតឱ្យ "កាត់ដេរសម្លៀកបំពាក់" ហើយត្រូវធ្វើរបាយការណ៍ប្រចាំខែអំពីស្ថានភាពផលិតកម្មរបស់រោងចក្រ ជូនក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល ។

ប្រការ៤: ក្រុមហ៊ុនត្រូវលើកបង្ហាញ "ផ្លាកឈ្មោះរោងចក្រ " របស់ខ្លួនជាអក្សរខ្មែរមានទំហំធំជាង និងនៅពីលើអក្សរផ្សេងទៀត នៅកន្លែងដែលងាយមើលឃើញនៅខាងមុខរោងចក្រ ។

ប្រការ៥: ការពង្រីកផលិតកម្ម ផ្លាស់ប្តូរមុខផលិតផល ផ្លាស់ប្តូរទីតាំងរោងចក្រ ឬ បង្កើតសាខារោងចក្រ ក្រុមហ៊ុនត្រូវសុំការអនុញ្ញាត ពីក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល ។

ប្រការ៦: ក្រុមហ៊ុន ត្រូវធានាសុវត្ថិភាពឧស្សាហកម្ម និង គុណភាពផលិតផល ព្រមទាំងត្រូវគោរពឱ្យបានម៉ឺងម៉ាត់ នូវច្បាប់ និងបទប្បញ្ញត្តិនានា ដែលពាក់ព័ន្ធនឹងផលិតកម្ម អាជីវកម្ម របស់ក្រុមហ៊ុន ។

ប្រការ៧: ក្រុមហ៊ុន ត្រូវសហការជាមួយមន្ត្រីមានសមត្ថកិច្ចនៃក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល ក្នុងគោលបំណងអនុវត្តប្រកាសនេះ ឱ្យមានប្រសិទ្ធភាព ។

ប្រការ៨: ក្នុងករណីរោងចក្រផ្អាកដំណើរការជាប់ៗគ្នាក្នុងរយៈពេល១២ខែ ឬ ប្រព្រឹត្តល្មើសច្បាប់ ឬ ល្មើសធ្ងន់ធ្ងរនឹងប្រការណាមួយ ដែលបានចែងខាងលើ ប្រកាសនេះនឹងត្រូវដកហូត ដោយគ្មានសំណងអ្វីឡើយ ។

ប្រការ៩: អគ្គនាយកឧស្សាហកម្ម ប្រធាននាយកដ្ឋានពាក់ព័ន្ធ ប្រធានមន្ទីរឧស្សាហកម្ម រ៉ែ និង ថាមពល រាជធានីភ្នំពេញ និងប្រធានក្រុមហ៊ុន វ៉ាយចិច ហ្គាមេន (ខេមបូឌា) ត្រូវអនុវត្តប្រកាសនេះ តាមមុខការរៀង១ខ្លួន ។

ប្រការ១០: ប្រកាសនេះមានអនុភាពគតិយុត្តិ ចាប់ពីថ្ងៃចុះហត្ថលេខា តទៅ ។

រដ្ឋមន្ត្រី

ស៊ុយ សែម

ចម្លងជូន :
- ទីស្តីការគណៈរដ្ឋមន្ត្រី
- រាជកិច្ច
- ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
- ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- ក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ
- ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និង សំណង់
- ក្រសួងបរិស្ថាន
- ក្រសួងពាណិជ្ជកម្ម
- សាលាក្រុងភ្នំពេញ

" ដើម្បីជូនជ្រាប "

- ដូចប្រការ ៩ " ដើម្បីអនុវត្ត"
- ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King

ក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល
Ministry of Industry, Mines and Energy
N° ៧៨១ ឧរថ.កឧ-ប្រក.

រាជធានីភ្នំពេញ, ថ្ងៃទី ១៨ ខែ តុលា ឆ្នាំ ២០០៥

# ប្រកាស

## រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/ រកត / ០៧០៤/ ១២៤ ចុះថ្ងៃទី១៥ ខែកក្កដា ឆ្នាំ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/ ០១៩៦/ ០៥ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើត ក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល
- បានឃើញអនុក្រឹត្យលេខ ៣៩ អនក្រ.បក ចុះថ្ងៃទី២៦ ខែមេសា ឆ្នាំ១៩៩៩ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅរបស់ក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល
- បានឃើញលិខិតលេខ ៤៧៣/០៥ គ.វ.ក ចុះថ្ងៃទី១៥.០២.២០០៥ របស់ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
- បានឃើញលិខិតលេខ ១៦១៥/០៥ គ.វ.ក ចុះថ្ងៃទី២០.០៥.២០០៥ របស់ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
- យោងពាក្យស្នើរបស់ក្រុមហ៊ុន អ៊ីសធើន សាន់ ថឹបែកខូ ចុះថ្ងៃទី២៥.០៨.២០០៥

# សំរេច

ប្រការ១: អនុញ្ញាតឱ្យក្រុមហ៊ុន អ៊ីសធើន សាន់ ថឹបែកខូ (EASTERN SUN TOBACCO CO., LTD.) តំណាងដោយលោក LIN QIN-MO សញ្ជាតិចិន(តៃវ៉ាន់) អាយុ៤៨ឆ្នាំ កាន់លិខិតឆ្លងដែនលេខ 130273979 ចុះថ្ងៃទី១៩.១០.២០០១ បង្កើតរោងចក្រ "ផលិតបារី" ដែលមានឈ្មោះថា "អ៊ីសធើន សាន់ ថឹបែកខូ (EASTERN SUN TOBACCO)" មានទីតាំងស្ថិតនៅ ឃុំស្វាយរលំ ស្រុកស្អាង ខេត្តកណ្តាល ។

៤៥ មហាវិថីព្រះនរោត្តម ខណ្ឌដូនពេញ ភ្នំពេញ ទូរស័ព្ទ : (៨៥៥) ២៣.២១១១៤១ , ទូរសារ : ៨៥៥.២៣.៤២៨២៦៣ .
45 Preah Norodom Boulevard, Khan Daun Penh, Phnom Penh, Phone : 855.23.211141 , Fax : 855.23.428263

ប្រការ២: ក្នុងកិច្ចដំណើរការក្រុមហ៊ុនត្រូវរៀបចំរោងចក្រទៅតាមប្លង់ ដែលបានតំកល់ទុកនៅក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល និងត្រូវផ្តល់លិខិតអនុញ្ញាតសាងសង់អាគារ មកក្រសួងក្នុងរយៈពេល ៣ខែ យ៉ាងយូរ ។

ប្រការ៣: រោងចក្រនេះត្រូវបានអនុញ្ញាតឱ្យ "ផលិតចារី" ហើយត្រូវធ្វើរបាយការណ៍ប្រចាំខែ អំពីស្ថានភាពផលិតកម្ម របស់រោងចក្រ ជូនក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល ។

ប្រការ៤: ក្រុមហ៊ុនត្រូវលើកបង្ហាញ "ផ្លាកឈ្មោះរោងចក្រ " របស់ខ្លួនជាអក្សរខ្មែរមានទំហំធំជាង និងនៅពីលើអក្សរ ផ្សេងទៀត នៅកន្លែងដែលងាយមើលឃើញនៅខាងមុខរោងចក្រ ។

ប្រការ៥: ការពង្រីកផលិតកម្ម ផ្លាស់ប្តូរមុខផលិតផល ផ្លាស់ប្តូរទីតាំងរោងចក្រ ឬ បង្កើតសាខារោងចក្រ ក្រុមហ៊ុនត្រូវ សុំការអនុញ្ញាត ពីក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល ។

ប្រការ៦: ក្រុមហ៊ុន ត្រូវធានាសុវត្ថិភាពឧស្សាហកម្ម និង គុណភាពផលិតផល ព្រមទាំងត្រូវគោរពឱ្យបានម៉ឺងម៉ាត់ នូវច្បាប់ និងបទប្បញ្ញត្តិនានា ដែលពាក់ព័ន្ធនឹងផលិតកម្ម អាជីវកម្ម របស់ក្រុមហ៊ុន ។

ប្រការ៧: ក្រុមហ៊ុន ត្រូវសហការជាមួយមន្ត្រីមានសមត្ថកិច្ចនៃក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល ក្នុងគោលបំណងអនុវត្ត ប្រកាសនេះ ឱ្យមានប្រសិទ្ធភាព ។

ប្រការ៨: ក្នុងករណីរោងចក្រផ្អាកដំណើរការជាប់១ឆ្នាំក្នុងរយៈពេល១២ខែ ឬ ប្រព្រឹត្តល្មើសច្បាប់ ឬ ល្មើសធ្ងន់ធ្ងរនឹងប្រការ ណាមួយ ដែលបានចែងខាងលើ ប្រកាសនេះនឹងត្រូវដកហូត ដោយគ្មានសំណងអ្វីឡើយ ។

ប្រការ៩: អគ្គនាយកឧស្សាហកម្ម ប្រធាននាយកដ្ឋានពាក់ព័ន្ធ ប្រធានមន្ទីរឧស្សាហកម្ម រ៉ែ និង ថាមពល ខេត្តកណ្តាល និងប្រធានក្រុមហ៊ុន អ៊ីសធើន សាន់ ចឺប៊ែកខូ ត្រូវអនុវត្តប្រកាសនេះ តាមមុខការរៀង១ខ្លួន ។

ប្រការ១០: ប្រកាសនេះមានអនុភាពគតិយុត្តិ ចាប់ពីថ្ងៃចុះហត្ថលេខា តទៅ ។ 

រដ្ឋមន្ត្រី

ស៊ុយ សែម

ចម្លងជូន :
-ទីស្តីការគណៈរដ្ឋមន្ត្រី
-រាជកិច្ច
-ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
-ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
-ក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ
-ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និង សំណង់
-ក្រសួងបរិស្ថាន
-ក្រសួងពាណិជ្ជកម្ម
-សាលាខេត្តកណ្តាល
" ដើម្បីជូនជ្រាប "
-ដូចប្រការ ៩ " ដើម្បីអនុវត្ត"
-ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King

ក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល
Ministry of Industry, Mines and Energy
N° ៣៤៤ ឧ.រ.ក.ច/ប្រក

រាជធានីភ្នំពេញ, ថ្ងៃទី ១៩ ខែ ៧ ឆ្នាំ ២០០៥

# ប្រកាស

## រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/ រកត / ០៧០៤/ ១២៤ ចុះថ្ងៃទី១៥ ខែកក្កដា ឆ្នាំ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ន.ស/ រកម/ ០១៩៦/ ០៥ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើត ក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល
- បានឃើញអនុក្រឹត្យលេខ ៣៥ អនក្រ.បក ចុះថ្ងៃទី២៦ ខែមេសា ឆ្នាំ១៩៩៩ ស្តីពីការរៀបចំនិងការប្រព្រឹត្តិទៅរបស់ក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល
- បានឃើញលិខិតលេខ ៣៣៩២/០៥ គ.វ.ក ចុះថ្ងៃទី២៩.០៩.២០០៥ របស់ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
- យោងពាក្យស្នើរបស់ក្រុមហ៊ុន រេនបូ ស្គ្រីន ព្រីនធីង ភីធីអ៊ី អិលធីឌី ចុះថ្ងៃទី០៦.០៦.២០០៥

## សំរេច

ប្រការ១: អនុញ្ញាតឱ្យក្រុមហ៊ុន រេនបូ ស្គ្រីន ព្រីនធីង ភីធីអ៊ី អិលធីឌី (RAINBOW SCREEN PRINTING PTE LTD.) តំណាងដោយ លោក ANG BOON CHEOW, EDWARD សញ្ជាតិសិង្ហបុរី ភេទប្រុស អាយុ៤៩ឆ្នាំ កាន់លិខិតឆ្លងដែនលេខ S1205391F ចុះថ្ងៃទី២៩.០៤.១៩៩៧ បង្កើតរោងចក្រ “បោះពុម្ពសម្លៀកបំពាក់” ដែលមានឈ្មោះថា “រេនបូ ស្គ្រីន ព្រីនធីង ភីធីអ៊ី អិលធីឌី (RAINBOW SCREEN PRINTING PTE LTD.)” មានទីតាំងស្ថិតនៅ ផ្លូវចោមចៅ ភូមិត្រពាំងថ្លឹង សង្កាត់ចោមចៅ ខណ្ឌដង្កោ រាជធានីភ្នំពេញ ។

ប្រការ២: ក្នុងកិច្ចដំណើរការក្រុមហ៊ុនត្រូវរៀបចំរោងចក្រទៅតាមប្លង់ ដែលបានតំកល់ទុកនៅក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល ។

ប្រការ៣: រោងចក្រនេះត្រូវបានអនុញ្ញាតឱ្យ“ បោះពុម្ពសម្លៀកបំពាក់” ហើយត្រូវធ្វើរបាយការណ៍ប្រចាំខែអំពីស្ថានភាព ផលិតកម្មរបស់រោងចក្រ ជូនក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល ។

ប្រការ៤: ក្រុមហ៊ុនត្រូវលើកបង្ហាញ “ផ្លាកឈ្មោះរោងចក្រ ” របស់ខ្លួនជាអក្សរខ្មែរមានទំហំធំជាង និងនៅពីលើអក្សរ ផ្សេងទៀត នៅកន្លែងដែលងាយមើលឃើញនៅខាងមុខរោងចក្រ ។

ប្រការ៥: ការពង្រីកផលិតកម្ម ផ្លាស់ប្តូរមុខផលិតផល ផ្លាស់ប្តូរទីតាំងរោងចក្រ ឬ បង្កើតសាខារោងចក្រ ក្រុមហ៊ុនត្រូវ សុំការអនុញ្ញាតពីក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល ។

ប្រការ៦: ក្រុមហ៊ុនត្រូវធានាសុវត្ថិភាពឧស្សាហកម្ម និង គុណភាពផលិតផល ព្រមទាំងត្រូវគោរពឱ្យបានម៉ឺងម៉ាត់ នូវច្បាប់ និងបទប្បញ្ញត្តិនានា ដែលពាក់ព័ន្ធនឹងផលិតកម្ម អាជីវកម្ម របស់ក្រុមហ៊ុន ។

ប្រការ៧ : ក្រុមហ៊ុន ត្រូវសហការជាមួយមន្ត្រីមានសមត្ថកិច្ចនៃក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល ក្នុងគោលបំណងអនុវត្ត ប្រកាសនេះ ឱ្យមានប្រសិទ្ធភាព ។

ប្រការ៨: ក្នុងករណីរោងចក្រផ្អាកដំណើរការជាប់ៗគ្នាក្នុងរយៈពេល១២ខែ ឬ ប្រព្រឹត្តល្មើសច្បាប់ ឬ ល្មើសធ្ងន់ធ្ងរនឹងប្រការ ណាមួយដែលបានចែងខាងលើ ប្រកាសនេះនឹងត្រូវដកហូត ដោយគ្មានសំណងអ្វីឡើយ ។

ប្រការ៩: អគ្គនាយកឧស្សាហកម្ម ប្រធាននាយកដ្ឋានពាក់ព័ន្ធ ប្រធានមន្ទីរឧស្សាហកម្ម រ៉ែ និង ថាមពល រាជធានីភ្នំពេញ និងប្រធានក្រុមហ៊ុន វេនបូ ស្រ្តីន ព្រីនធីង ភីធីអ៊ី អិលធីឌី ត្រូវអនុវត្តប្រកាសនេះ តាមមុខការរៀងៗខ្លួន ។

ប្រការ១០: ប្រកាសនេះមានអនុភាពតតិយុត្តិ ចាប់ពីថ្ងៃចុះហត្ថលេខា តទៅ ។

រដ្ឋមន្ត្រី

ស៊ុយ_សែម

ចម្លងជូន :
-ទីស្តីការគណៈរដ្ឋមន្ត្រី
-រាជកិច្ច
-ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
-ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
-ក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ
-ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និង សំណង់
-ក្រសួងបរិស្ថាន
-ក្រសួងពាណិជ្ជកម្ម
-សាលាក្រុងភ្នំពេញ
“ ដើម្បីជូនជ្រាប ”
- ដូចប្រការ ៩ “ ដើម្បីអនុវត្ត”
-ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King

ក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល
Ministry of Industry, Mines and Energy
N° ៨០៩ ឧរម.កន.ប្រក

រាជធានីភ្នំពេញ, ថ្ងៃទី២៥ ខែ តុលា ឆ្នាំ២០០៥

# ប្រកាស

## រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/ រកត / ០៧០៤/ ១២៤ ចុះថ្ងៃទី១៥ ខែកក្កដា ឆ្នាំ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/ ០១៩៦/ ០៥ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើត ក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល
- បានឃើញអនុក្រឹត្យលេខ ៣៥ អនក្រ.បក ចុះថ្ងៃទី២៦ ខែមេសា ឆ្នាំ១៩៩៩ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅរបស់ក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល
- បានឃើញលិខិតលេខ ៣២៤៤/០៥ គ.វ.ក ចុះថ្ងៃទី២២.០៩.២០០៥ របស់ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
- យោងពាក្យស្នើរបស់ក្រុមហ៊ុន ស៊ាង ទូ (ខេមបូឌា) មេឌីខល អេឃ្វីបមេន ចុះថ្ងៃទី០១.០៨.២០០៥

# សម្រេច

ប្រការ១: អនុញ្ញាតឱ្យក្រុមហ៊ុន ស៊ាង ទូ (ខេមបូឌា) មេឌីខល អេឃ្វីបមេន (SHUANG TU (CAMBODIA) MEDICAL EQUIPMENT CO., LTD.) តំណាងដោយ លោក LI ZHONGHUA សញ្ជាតិចិន អាយុ៥៦ឆ្នាំ កាន់លិខិតឆ្លងដែនលេខ G12246242 ចុះថ្ងៃទី០៨.០៥.២០០៥ បង្កើតរោងចក្រ "ផលិតសំភារៈ បរិក្ខារពេទ្យ" ដែលមានឈ្មោះថា "ស៊ាង ទូ (ខេមបូឌា) មេឌីខល អេឃ្វីបមេន ( SHUANG TU (CAMBODIA) MEDICAL EQUIPMENT )" មានទីតាំងស្ថិតនៅអាគារលេខ១៨ នៃសួនឧស្សាហកម្មកាណាឌីយ៉ា ភូមិត្រពាំងថ្លឹង សង្កាត់ចោមចៅ ខណ្ឌដង្កោ រាជធានីភ្នំពេញ ។

៤៥ មហាវិថីព្រះនរោត្តម ខ័ណ្ឌដូនពេញ ភ្នំពេញ ទូរស័ព្ទ : (៨៥៥) ២៣.២១១១៤១ , ទូរសារ : ៨៥៥.២៣.៤២៨២៦៣
45 Preah Norodom Boulevard, Khan Daun Penh, Phnom Penh, Phone : 855.23.211141 , Fax : 855.23.428263

ប្រការ២: ក្នុងកិច្ចដំណើរការ ក្រុមហ៊ុនត្រូវរៀបចំរោងចក្រទៅតាមប្លង់ ដែលបានតំកល់ទុកនៅក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល ។

ប្រការ៣: រោងចក្រនេះត្រូវបានអនុញ្ញាតឱ្យ "ផលិតសំភារៈបរិក្ខារពេទ្យ" ហើយត្រូវធ្វើរបាយការណ៍ប្រចាំខែ អំពីស្ថានភាព ផលិតកម្មរបស់រោងចក្រ ជូនក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល ។

ប្រការ៤: ក្រុមហ៊ុនត្រូវលើកបង្ហាញ "ផ្លាកឈ្មោះរោងចក្រ" របស់ខ្លួនជាអក្សរខ្មែរមានទំហំធំជាង និងនៅពីលើអក្សរ ផ្សេងទៀត នៅកន្លែងដែលងាយមើលឃើញនៅខាងមុខ រោងចក្រ ។

ប្រការ៥: ការពង្រីកផលិតកម្ម ផ្លាស់ប្តូរមុខផលិតផល ផ្លាស់ប្តូរទីតាំងរោងចក្រ ឬ បង្កើតសាខារោងចក្រ ក្រុមហ៊ុនត្រូវ សុំការអនុញ្ញាតពីក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល ។

ប្រការ៦: ក្រុមហ៊ុនត្រូវធានាសុវត្ថិភាពឧស្សាហកម្ម និង គុណភាពផលិតផល ព្រមទាំងត្រូវគោរពឱ្យបានម៉ឺងម៉ាត់ នូវច្បាប់ និងបទប្បញ្ញត្តិនានា ដែលពាក់ព័ន្ធនឹងផលិតកម្ម អាជីវកម្ម របស់ក្រុមហ៊ុន ។

ប្រការ៧: ក្រុមហ៊ុន ត្រូវសហការជាមួយមន្ត្រីមានសមត្ថកិច្ចនៃក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល ក្នុងគោលបំណងអនុវត្ត ប្រកាសនេះ ឱ្យមានប្រសិទ្ធភាព ។

ប្រការ៨: ក្នុងករណីរោងចក្រ ផ្អាកដំណើរការជាប់១ឆ្នាំ ក្នុងរយៈពេល១២ខែ ឬប្រព្រឹត្តល្មើសច្បាប់ ឬ ល្មើសធ្ងន់ធ្ងរនឹងប្រការ ណាមួយដែលបានចែងខាងលើ ប្រកាសនេះនឹងត្រូវដកហូត ដោយគ្មានសំណងអ្វីឡើយ ។

ប្រការ៩: អគ្គនាយកឧស្សាហកម្ម ប្រធាននាយកដ្ឋានពាក់ព័ន្ធ ប្រធានមន្ទីរឧស្សាហកម្ម រ៉ែ និង ថាមពល រាជធានីភ្នំពេញ និងប្រធានក្រុមហ៊ុន ស៊ាង ទូ (ខេមបូឌា) មេឌីខល អេឃ្វីបមេន ត្រូវអនុវត្តប្រកាសនេះ តាមមុខការរៀង១ខ្លួន ។

ប្រការ១០: ប្រកាសនេះមានអនុភាពគតិយុត្តិ ចាប់ពីថ្ងៃចុះហត្ថលេខា តទៅ ។

រដ្ឋមន្ត្រី

ស៊ុយ សែម

ចម្លងជូន :
-ទីស្តីការគណៈរដ្ឋមន្ត្រី
-រាជកិច្ច
-ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
-ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
-ក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ
-ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និង សំណង់
-ក្រសួងបរិស្ថាន
-ក្រសួងពាណិជ្ជកម្ម
-សាលាក្រុងភ្នំពេញ
" ដើម្បីជូនជ្រាប"
-ដូចប្រការ ៩ " ដើម្បីអនុវត្ត"
-ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King

ក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល
Ministry of Industry, Mines and Energy
N° ៨១០ ឧស៥. កឱ-ប្រក.

រាជធានីភ្នំពេញ, ថ្ងៃទី២៥ ខែ តុលា ឆ្នាំ២០០៥

# ប្រកាស

## រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/ រកត / ០៧០៤/ ១២៤ ចុះថ្ងៃទី១៥ ខែកក្កដា ឆ្នាំ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/ ០១៩៦/ ០៥ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើត ក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល
- បានឃើញអនុក្រឹត្យលេខ ៣៥ អនក្រ.បក ចុះថ្ងៃទី២៦ ខែមេសា ឆ្នាំ១៩៩៩ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅរបស់ក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល
- បានឃើញលិខិតលេខ ៣២៤៨/០៥ គ.វ.ក ចុះថ្ងៃទី២២.០៩.២០០៥ របស់ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
- យោងពាក្យស្នើរបស់ក្រុមហ៊ុន ចាង តៃ អ៊ិនធើណេសិនណល ខប ចុះថ្ងៃទី១០.១០.២០០៥

## សំរេច

ប្រការ១: អនុញ្ញាតឱ្យក្រុមហ៊ុន ចាង តៃ អ៊ិនធើណេសិនណល ខប (CHANG TAI INTERNATIONAL CORP.) តំណាងដោយ លោក YEH, MU SEN សញ្ជាតិចិន (តៃវ៉ាន់) អាយុ៣៦ឆ្នាំ កាន់លិខិតឆ្លងដែនលេខ 200527214 ចុះថ្ងៃទី២៦.០៣.២០០៣ បង្កើតរោងចក្រ "កាត់ដេរសម្លៀកបំពាក់" ដែលមានឈ្មោះថា " ចាង តៃ អ៊ិនធើណេសិនណល ខប (CHANG TAI INTERNATIONAL CORP.) មានទីតាំងស្ថិតនៅ សួនឧស្សាហកម្មកាណាឌីយ៉ា អាគារលេខ C១១ និងលេខ២១ ភូមិត្រពាំងថ្លឹង សង្កាត់ចោមចៅ ខណ្ឌដង្កោ រាជធានីភ្នំពេញ ។

៤៥ មហាវិថីព្រះនរោត្តម ខ័ណ្ឌដូនពេញ ភ្នំពេញ ទូរស័ព្ទ : (៨៥៥) ២៣.២១១១៤១ , ទូរសារ : ៨៥៥.២៣.៤២៨២៦៣
45 Preah Norodom Boulevard, Khan Daun Penh, Phnom Penh, Phone : 855.23.211141 , Fax : 855.23.428263

ប្រការ២: ក្នុងកិច្ចដំណើរការ ក្រុមហ៊ុនត្រូវរៀបចំរោងចក្រទៅតាមប្លង់ ដែលបានតំកល់ទុកនៅក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល ។

ប្រការ៣: រោងចក្រនេះ ត្រូវបានអនុញ្ញាតឱ្យ "កាត់ដេរសម្លៀកបំពាក់" ហើយត្រូវធ្វើរបាយការណ៍ប្រចាំខែអំពីស្ថានភាព ផលិតកម្មរបស់រោងចក្រ ជូនក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល ។

ប្រការ៤: ក្រុមហ៊ុនត្រូវលើកបង្ហាញ "ផ្លាកឈ្មោះរោងចក្រ" របស់ខ្លួនជាអក្សរខ្មែរមានទំហំធំជាង និងនៅពីលើអក្សរ ផ្សេងទៀត នៅកន្លែងដែលងាយមើលឃើញនៅខាងមុខរោងចក្រ ។

ប្រការ៥: ការពង្រីកផលិតកម្ម ផ្លាស់ប្តូរមុខផលិតផល ផ្លាស់ប្តូរទីតាំងរោងចក្រ ឬ បង្កើតសាខារោងចក្រ ក្រុមហ៊ុនត្រូវ សុំការអនុញ្ញាត ពីក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល ។

ប្រការ៦: ក្រុមហ៊ុន ត្រូវធានាសុវត្ថិភាពឧស្សាហកម្ម និង គុណភាពផលិតផល ព្រមទាំងត្រូវគោរពឱ្យបានម៉ឺងម៉ាត់ នូវច្បាប់ និងបទប្បញ្ញត្តិនានា ដែលពាក់ព័ន្ធនឹងផលិតកម្ម អាជីវកម្ម របស់ក្រុមហ៊ុន ។

ប្រការ៧: ក្រុមហ៊ុន ត្រូវសហការជាមួយមន្ត្រីមានសមត្ថកិច្ចនៃក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល ក្នុងគោលបំណងអនុវត្ត ប្រកាសនេះ ឱ្យមានប្រសិទ្ធភាព ។

ប្រការ៨: ក្នុងករណីរោងចក្រផ្អាកដំណើរការជាប់១ឆ្នាំក្នុងរយៈពេល១២ខែ ឬ ប្រព្រឹត្តល្មើសច្បាប់ ឬ ល្មើសចំពោះនឹងប្រការ ណាមួយ ដែលបានចែងខាងលើ ប្រកាសនេះនឹងត្រូវដកហូត ដោយគ្មានសំណងអ្វីឡើយ ។

ប្រការ៩: អគ្គនាយកឧស្សាហកម្ម ប្រធាននាយកដ្ឋានពាក់ព័ន្ធ ប្រធានមន្ទីរឧស្សាហកម្ម រ៉ែ និង ថាមពល រាជធានីភ្នំពេញ និងប្រធានក្រុមហ៊ុន ចាង តៃ អ៊ិនធើណេសិនណល ខប ត្រូវអនុវត្តប្រកាសនេះ តាមមុខការរៀង១ខ្លួន ។

ប្រការ១០: ប្រកាសនេះមានអនុភាពគតិយុត្តិ ចាប់ពីថ្ងៃចុះហត្ថលេខា តទៅ ។

រដ្ឋមន្ត្រី

ស៊ុយ សែម

ចម្លងជូន :
-ទីស្តីការគណៈរដ្ឋមន្ត្រី
-រាជកិច្ច
-ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
-ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
-ក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ
-ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និង សំណង់
-ក្រសួងបរិស្ថាន
-ក្រសួងពាណិជ្ជកម្ម
-សាលាក្រុងភ្នំពេញ
" ដើម្បីជូនជ្រាប "
-ដូចប្រការ ៩ " ដើម្បីអនុវត្ត"
-ឯកសារ-កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**
**Kingdom of Cambodia**
**Nation Religion King**

**ក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល**
**Ministry of Industry, Mines and Energy**
N° ៤១១ ឧរថ.កឧ.ប្រក

រាជធានីភ្នំពេញ, ថ្ងៃទី២៥ ខែ តុលា ឆ្នាំ២០០៥

# ប្រកាស

## រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/ រកត / ០៧០៤/ ១២៤ ចុះថ្ងៃទី១៥ ខែកក្កដា ឆ្នាំ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/ ០១៩៦/ ០៥ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើត ក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល
- បានឃើញអនុក្រឹត្យលេខ ៣៥ អនក្រ.បក ចុះថ្ងៃទី២៦ ខែមេសា ឆ្នាំ១៩៩៩ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល
- បានឃើញលិខិតលេខ ៣៣៤១/០៥ គ.រ.ក ចុះថ្ងៃទី២៨.០៩.២០០៥ របស់ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
- យោងពាក្យស្នើរបស់ក្រុមហ៊ុន មិញ ហ៊ុយ ហ្គាមេន ចុះថ្ងៃទី០៦.១០.២០០៥

# សំរេច

<u>ប្រការ១:</u> អនុញ្ញាតឱ្យក្រុមហ៊ុន មិញ ហ៊ុយ ហ្គាមេន ( MING HUI GARMENT CO., LTD.) តំណាងដោយលោក LI ZHONG MING សញ្ជាតិចិន អាយុ៤៤ឆ្នាំ កាន់លិខិតឆ្លងដែនលេខ PCHN 148366844 ចុះថ្ងៃទី ២០.០៧.២០០៤ បង្កើតរោងចក្រ "កាត់ដេរសម្លៀកបំពាក់" ដែលមានឈ្មោះថា " មិញ ហ៊ុយ ហ្គាមេន ( MING HUI GARMENT )"មានទីតាំងស្ថិតនៅ ភូមិថ្មី សង្កាត់ស្ទឹងមានជ័យ ខណ្ឌមានជ័យ រាជធានីភ្នំពេញ ។

<u>ប្រការ២:</u> ក្នុងកិច្ចដំណើរការ ក្រុមហ៊ុនត្រូវរៀបចំរោងចក្រទៅតាមប្លង់ ដែលបានតំកល់ទុកនៅក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល ។

ប្រការ៣: រោងចក្រនេះត្រូវបានអនុញ្ញាតឱ្យ "កាត់ដេរសម្លៀកបំពាក់" ហើយត្រូវធ្វើរបាយការណ៍ប្រចាំខែអំពីស្ថានភាពផលិតកម្មរបស់រោងចក្រ ជូនក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល ។

ប្រការ៤: ក្រុមហ៊ុនត្រូវលើកបង្ហាញ "ផ្លាកឈ្មោះរោងចក្រ " របស់ខ្លួនជាអក្សរខ្មែរមានទំហំធំជាង និងនៅពីលើអក្សរផ្សេងទៀត នៅកន្លែងដែលងាយមើលឃើញនៅខាងមុខ រោងចក្រ ។

ប្រការ៥: ការពង្រីកផលិតកម្ម ផ្លាស់ប្តូរមុខផលិតផល ផ្លាស់ប្តូរទីតាំងរោងចក្រ ឬ បង្កើតសាខារោងចក្រ ក្រុមហ៊ុនត្រូវសុំការអនុញ្ញាតពីក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល ។

ប្រការ៦: ក្រុមហ៊ុនត្រូវធានាសុវត្ថិភាពឧស្សាហកម្ម និង គុណភាពផលិតផល ព្រមទាំងត្រូវគោរពឱ្យបានម៉ឺងម៉ាត់ នូវច្បាប់ និងបទប្បញ្ញត្តិនានា ដែលពាក់ព័ន្ធនឹងផលិតកម្ម អាជីវកម្ម របស់ក្រុមហ៊ុន ។

ប្រការ៧: ក្រុមហ៊ុន ត្រូវសហការជាមួយមន្ត្រីមានសមត្ថកិច្ចនៃក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល ក្នុងគោលបំណងអនុវត្តប្រកាសនេះ ឱ្យមានប្រសិទ្ធភាព ។

ប្រការ៨: ក្នុងករណីរោងចក្រ ផ្អាកដំណើរការជាប់១ឆ្នាំ ក្នុងរយៈពេល១២ខែ ឬប្រព្រឹត្តល្មើសច្បាប់ ឬ ល្មើសចំពោះប្រការណាមួយដែលបានចែងខាងលើ ប្រកាសនេះនឹងត្រូវដកហូត ដោយគ្មានសំណងអ្វីឡើយ ។

ប្រការ៩: អគ្គនាយកឧស្សាហកម្ម ប្រធាននាយកដ្ឋានពាក់ព័ន្ធ ប្រធានមន្ទីរឧស្សាហកម្ម រ៉ែ និង ថាមពល រាជធានីភ្នំពេញ និងប្រធានក្រុមហ៊ុន មិញ ហ៊ុយ ហ្គាមេន ត្រូវអនុវត្តប្រកាសនេះ តាមមុខការរៀងៗខ្លួន ។

ប្រការ១០: ប្រកាសនេះមានអនុភាពគតិយុត្តិ ចាប់ពីថ្ងៃចុះហត្ថលេខា តទៅ ។

រដ្ឋមន្ត្រី

ស៊ុយ សែម

ចម្លងជូន :

-ទីស្តីការគណៈរដ្ឋមន្ត្រី
-រាជកិច្ច
-ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
-ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
-ក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ
-ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និង សំណង់
-ក្រសួងបរិស្ថាន
-ក្រសួងពាណិជ្ជកម្ម
-សាលាក្រុងភ្នំពេញ
" ដើម្បីជូនជ្រាប"
-ដូចប្រការ ៩ " ដើម្បីអនុវត្ត"
-ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King

ក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល
Ministry of Industry, Mines and Energy
N° ៤១៧ ឧស្ស.ករ.ប្រក.

រាជធានីភ្នំពេញ, ថ្ងៃទី២៥ ខែ តុលា ឆ្នាំ ២០០៥

# ប្រកាស

## រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/ រកត / ០៧០៤/ ១២៤ ចុះថ្ងៃទី១៥ ខែកក្កដា ឆ្នាំ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/ ០១៩៦/ ០៥ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើត ក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល
- បានឃើញអនុក្រឹត្យលេខ ៣៥ អនក្រ.បក ចុះថ្ងៃទី២៦ ខែមេសា ឆ្នាំ១៩៩៩ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅរបស់ក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល
- បានឃើញលិខិតលេខ ៣១៦៥/០៥ គ.វ.ក ចុះថ្ងៃទី១៤.០៩.២០០៥ របស់ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
- យោងពាក្យស្នើរបស់ក្រុមហ៊ុន ឌី អឹម អេ (ខេមបូឌា) ចុះថ្ងៃទី១៩.០៧.២០០៥

## សំរេច

ប្រការ១: អនុញ្ញាតឱ្យក្រុមហ៊ុន ឌី អឹម អេ (ខេមបូឌា) (DMA (CAMBODIA) CO.,LTD.) តំណាងដោយលោក MAO JINQUAN សញ្ជាតិ ចិន អាយុ៤១ឆ្នាំ កាន់លិខិតឆ្លងដែនលេខ G05511285 ចុះថ្ងៃទី២១.១១.២០០២ បង្កើតរោងចក្រ "កាត់ដេរសម្លៀកបំពាក់ "ដែលមានឈ្មោះថា "ឌី អឹម អេ (ខេមបូឌា) ( DMA (CAMBODIA) LTD. )" មានទីតាំងស្ថិតនៅ បន្ទាយC7 ភូមិដំណាក់ធំ សង្កាត់ភ្នំពេញថ្មី ខណ្ឌឬស្សីកែវ រាជធានីភ្នំពេញ ។

៤៥ មហាវិថីព្រះនរោត្តម ខណ្ឌដូនពេញ ភ្នំពេញ ទូរស័ព្ទ : (៨៥៥) ២៣.២១១១៤១ , ទូរសារ : ៨៥៥.២៣.៤២៨២៦៣
45 Preah Norodom Boulevard, Khan Daun Penh, Phnom Penh, Phone : 855.23.211141 , Fax : 855.23.428263

ប្រការ២: ក្នុងកិច្ចដំណើរការក្រុមហ៊ុនត្រូវរៀបចំរោងចក្រទៅតាមប្លង់ ដែលបានតំកល់ទុកនៅក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល ។

ប្រការ៣: រោងចក្រនេះត្រូវបានអនុញ្ញាតឱ្យ "កាត់ដេរសម្លៀកបំពាក់" ហើយត្រូវធ្វើរបាយការណ៍ប្រចាំខែអំពីស្ថានភាព ផលិតកម្មរបស់រោងចក្រ ជូនក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល ។

ប្រការ៤: ក្រុមហ៊ុនត្រូវលើកបង្ហាញ "ផ្លាកឈ្មោះរោងចក្រ " របស់ខ្លួនជាអក្សរខ្មែរមានទំហំធំជាង និងនៅពីលើអក្សរ ផ្សេងទៀត នៅកន្លែងដែលងាយមើលឃើញនៅខាងមុខរោងចក្រ ។

ប្រការ៥: ការពង្រីកផលិតកម្ម ផ្លាស់ប្តូរមុខផលិតផល ផ្លាស់ប្តូរទីតាំងរោងចក្រ ឬ បង្កើតសាខារោងចក្រ ក្រុមហ៊ុនត្រូវ សុំការអនុញ្ញាត ពីក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល ។

ប្រការ៦: ក្រុមហ៊ុន ត្រូវធានាសុវត្ថិភាពឧស្សាហកម្ម និង គុណភាពផលិតផល ព្រមទាំងត្រូវគោរពឱ្យបានម៉ឺងម៉ាត់ នូវច្បាប់ និងបទប្បញ្ញត្តិនានា ដែលពាក់ព័ន្ធនឹងផលិតកម្ម អាជីវកម្ម របស់ក្រុមហ៊ុន ។

ប្រការ៧: ក្រុមហ៊ុន ត្រូវសហការជាមួយមន្ត្រីមានសមត្ថកិច្ចនៃក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល ក្នុងគោលបំណងអនុវត្ត ប្រកាសនេះ ឱ្យមានប្រសិទ្ធភាព ។

ប្រការ៨: ក្នុងករណីរោងចក្រផ្អាកដំណើរការជាប់ៗគ្នាក្នុងរយៈពេល១២ខែ ឬ ប្រព្រឹត្តល្មើសច្បាប់ ឬ ល្មើសធ្ងន់ធ្ងរនឹងប្រការ ណាមួយ ដែលបានចែងខាងលើ ប្រកាសនេះនឹងត្រូវដកហូត ដោយគ្មានសំណងអ្វីឡើយ ។

ប្រការ៩: អគ្គនាយកឧស្សាហកម្ម ប្រធាននាយកដ្ឋានពាក់ព័ន្ធ ប្រធានមន្ទីរឧស្សាហកម្ម រ៉ែ និង ថាមពល រាជធានីភ្នំពេញ និងប្រធានក្រុមហ៊ុន ឌី អឹម អេ (ខេមបូឌា) ត្រូវអនុវត្តប្រកាសនេះ តាមមុខការរៀងៗខ្លួន ។

ប្រការ១០: ប្រកាសនេះមានអនុភាពតតិយុត្តិ ចាប់ពីថ្ងៃចុះហត្ថលេខា តទៅ ។

រដ្ឋមន្ត្រី

ស៊ុយ សែម

ចម្លងជូន :
-ទីស្តីការគណៈរដ្ឋមន្ត្រី
-រាជកិច្ច
-ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
-ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
-ក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ
-ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និង សំណង់
-ក្រសួងបរិស្ថាន
-ក្រសួងពាណិជ្ជកម្ម
-សាលាក្រុងភ្នំពេញ
" ដើម្បីជូនជ្រាប "
-ដូចប្រការ ៩ " ដើម្បីអនុវត្ត"
-ឯកសារ-កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**
ជាតិ សាសនា ព្រះមហាក្សត្រ

**រាជរដ្ឋាភិបាលកម្ពុជា**
ក្រសួងមហាផ្ទៃ

លេខ ១៤៣៣ ប្រ.ក

# ប្រកាស
# ស្តីពី
# ការប្រើប្រាស់ផ្លាកលេខថ្មីសំគាល់យានជំនិះ និងជលយាននគរបាលជាតិ និងការគ្រប់គ្រងបញ្ជីប័ណ្ណសំគាល់យានជំនិះគ្រប់ប្រភេទ

## <u>សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ</u>

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស រកត ០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/ រកម/០១៩៦/០៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញក្រឹត្យលេខ ៦៨ ក្រ ចុះថ្ងៃទី ៣១ ខែ សីហា ឆ្នាំ ១៩៩១ ដែលប្រកាសអោយប្រើច្បាប់ស្តីពីចរាចរផ្លូវគោក
- បានឃើញអនុក្រឹត្យលេខ ១៦ អនក្រ ចុះថ្ងៃទី ២០ ខែ ធ្នូ ឆ្នាំ ១៩៩៣ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងមហាផ្ទៃ
- យោងអនុក្រឹត្យលេខ ៧៧ អនក្រ.បក ចុះថ្ងៃទី ២៨ ខែ វិច្ឆិកា ឆ្នាំ ២០០៣ របស់រាជរដ្ឋាភិបាល ស្តីពីការចេញផ្លាកលេខ សំគាល់យានជំនិះ
- តាមសំណើររបស់អគ្គស្នងការនគរបាលជាតិ

## <u>សំរេច</u>

### <u>ប្រការ ១ កំណត់ទូទៅ</u>

១.១. ប្រគល់សិទ្ធិជូន អគ្គស្នងការនគរបាលជាតិ រៀបចំផ្លាស់ប្តូរប័ណ្ណសំគាល់ និងចេញផ្លាកលេខថ្មី យានយន្តនិងជលយានជាកម្មសិទ្ធិរបស់ក្រសួងមហាផ្ទៃ ប្រើប្រាស់ជាមធ្យោបាយ សំរាប់ការងារ ការពារសន្តិសុខជាតិ សណ្តាប់ធ្នាប់សង្គម និងត្រូវរបូកសរុបរាយការណ៍ជូនក្រសួង ជារៀងរាល់ខែ ។

១.២. យានយន្តគ្រប់ប្រភេទ ដែលជាកម្មសិទ្ធិរបស់ក្រសួងមហាផ្ទៃរួមមាន រដ្ឋបំពាក់ ក្រសួងចំណាយថវិកាទិញផ្ទាល់ អំណោយពីអង្គការនានា និងសប្បុរសជន ហើយត្រូវបានចុះបញ្ជីសារពើភ័ណ្ឌនៅក្រសួងមហាផ្ទៃ ។

១.៣ យានយន្ត និងជលយាន ដែលត្រូវបានផ្តល់ប័ណ្ណសំគាល់ និង ផ្លាកលេខក្រសួងមហាផ្ទៃ ត្រូវបានបែងចែកប្រភេទដូចខាងក្រោម :

- ប្រភេទទី ១. ទោចក្រយានយន្ត និងត្រីចក្រយានយន្ត
- ប្រភេទទី ២. រថយន្តធុនតូច ( ទេសចរណ៍ )
- ប្រភេទទី ៣. រថយន្តធុន មធ្យម ធ្ងន់ យានយន្តប្បករណ៍ និងប្រយុទ្ធ
- ប្រភេទទី ៤. រ៉ឺម៉ក - សឺមីរ៉ឺម៉ក ( យានសំរាប់ផ្ទុកជាប់ក្បាលរថយន្តសណ្តោង )
- ប្រភេទទី ៥. ជលយាន

**ប្រការ ២.** រូបភាពផ្លាកលេខ

២.១. ផ្លាកលេខយានយន្តមាន ៤ ប្រភេទ និងផ្លាកលេខជលយានមាន ១ ប្រភេទ មានទំហំ មានអក្សរដើមជាអក្សរខ្មែរ មានលេខកូដ លេខសំគាល់ អក្សរឡាតាំង ពណ៌ សញ្ញាសំគាល់ ដូចខាងក្រោម :

ក ១. ផ្លាកលេខសំរាប់ទោចក្រយានយន្ត និងត្រីចក្រយានយន្ត

" នគរបាល 1.0001 POLICE "

ក ២. ផ្លាកលេខសំរាប់រថយន្តធុនតូច ( ទេសចរណ៍ )

" នគរបាល 2.0001 POLICE "

ក ៣. ផ្លាកលេខសំរាប់រថយន្តធុនមធ្យម ធ្ងន់ យានយន្តប្បករណ៍ និងប្រយុទ្ធ

" នគរបាល 3.0001 POLICE "

ក ៤. ផ្លាកលេខសំរាប់ រ៉ឺម៉ក-សឺមីរ៉ឺម៉ក ( យានសំរាប់ផ្ទុកជាប់ក្បាលរថយន្តសណ្តោង )

" នគរបាល 4.0001 POLICE "

ក ៥. ផ្លាកលេខសំរាប់ជលយាន

" នគរបាល 5.0001 POLICE "

ខ ទំហំផ្លាកលេខ :

ខ ១. - ផ្លាកលេខទោចក្រយានយន្ត ត្រីចក្រយានយន្តទំហំ ២០០មម x ១២០មម

ខ ២. - ផ្លាកលេខរថយន្តធុនតូច ( ទេសចរណ៍ ) ខាងមុខ និងខាងក្រោយ ទំហំស្មើគ្នា ៣០៥មម x ១៦០មម

ខ ៣. - ផ្លាកលេខរថយន្តធុនមធ្យម ធុនធំ យានយន្តប្បករណ៍ និងប្រយុទ្ធ រ៉ឺម៉ក-សឺមីរ៉ឺម៉ក ទំហំ :

- ផ្លាកមុខ ៣៦០មម x ១៩០មម
- ផ្លាកក្រោយ ៣៦០មម x ២២០មម

ខ ៤. - ផ្លាកលេខជលយានមានចំនួនពីរ មានទំហំប៉ុនគ្នា ៣៦០មម x ២២០មម ដាក់នៅសងខាងផ្នែកខាងក្រោមនៃជញ្ជាំងមុខមានកំពស់ពីតែមចំនួន ២០មម ។

គ. តួអក្សរ

គ ១. អក្សរខ្មែរ :

- ទោចក្រយានយន្ត និងត្រីចក្រយានយន្តកំពស់ ២២មម សង្កត់ផុស ។
- រថយន្តធុនតូច ធុនមធ្យម ធុនធំ យានយន្តប្បករណ៍ និងប្រយុទ្ធ រ៉ឺម៉ក សឺមីរ៉ឺម៉ក និងជលយានកំពស់ ៤៥មម សង្កត់ផុស ។

គ ២. អក្សរឡាតាំង :

- ទោចក្រយានយន្ត និងត្រីចក្រយានយន្ត កំពស់ ៨មម ។
- រថយន្តធុនតូច ធុនមធ្យម ធុនធំ យានយន្តប្បករណ៍ និងប្រយុទ្ធ សឺមីរ៉ឺម៉ក និង ជលយានកំពស់ ១២មម ។

ឃ. កំពស់លេខ :

- ទោចក្រយានយន្ត និងត្រីចក្រយានយន្ត កំពស់ ៤៥មម ។
- រថយន្តធុនតូច ធុនមធ្យម ធុនធំ យានយន្តប្បករណ៍ និងប្រយុទ្ធ សឺមីរ៉ឺម៉ក និង ជលយាន កំពស់ ៧០មម ។

ង. ពណ៌ :

ផ្លាកលេខគ្រប់ប្រភេទនៃយានយន្ត និងជលយាននគរបាលជាតិ ជាកម្មសិទ្ធិរបស់ក្រសួង មហាផ្ទៃ មានផ្ទៃពណ៌ ស អក្សរនិងលេខពណ៌ក្រហម មានសញ្ញារាជសីហ៍សំគាល់ផ្នែកខាងស្តាំ ជ្រុងខាងលើនៃផ្លាក ។

**ប្រការ ៣ : ការទូទាត់លើតំលៃផ្លាកលេខ**

៣.១. សាមុីអង្គភាពនីមួយៗដែលប្រើប្រាស់យានយន្តគ្រប់ប្រភេទចំណុះ អគ្គស្នងការដ្ឋាននគរបាលជាតិនៃក្រសួងមហាផ្ទៃមកសុំធ្វើការចុះបញ្ជីផ្តល់ផ្លាកលេខត្រូវស្នើសុំថវិកាពីក្រសួងដោយខ្លួនឯង មកបង់អោយនាយកដ្ឋានជំនាញដើម្បីផលិតជូនតាមតំលៃដូចខាងក្រោម :

- ទោចក្រយានយន្ត និងត្រីចក្រយានយន្ត តំលៃ ៤២.០០០ រៀល
- រថយន្តធុនតូច ( ទេសចរណ៍ ) ផ្លាកលេខចំនួនពីរ ( មុខក្រោយ ) តំលៃ ៩២.៤០០រៀល
- រថយន្តធុនមធ្យម ធុនធ្ងន់ យានយន្តឧបករណ៍ និងប្រយុទ្ធ សីមីរ៉ឺម៉ក និងជលយានផ្លាក ចំនួនពីរ តំលៃ ១១៣.៤០០ រៀល ។
- រូបសញ្ញានគរបាលជាតិ ( រាជសីហ៍ ) ចំនួនមួយតំលៃ ៣៧.៨០០ រៀល ។
- តំលៃខាងលើអាចមានការប្រែប្រួលនិងកំណត់ជាថ្មី តាមអត្រាឡើងចុះនៃវត្ថុធាតុដើម តាមសំណើរបស់អគ្គស្នងការនគរបាលជាតិ ។

**ប្រការ ៤.** លក្ខណប្រើប្រាស់ :

៤.១. យានយន្ត និងជលយានគ្រប់ប្រភេទ ដែលបំរើអោយអង្គភាពនគរបាលជាតិ ក្នុងប្រភេទដឹកជញ្ជូនកងអង្គរក្ស សង្គ្រោះ បង្កានិងពន្លត់អគ្គីភ័យ រក្សាសណ្តាប់ធ្នាប់សាធារណៈ រក្សាសណ្តាប់ធ្នាប់ចរាចរ បង្កានិងបង្ក្រាបបទល្មើសក្រៅពីផ្លាកលេខដែលបានពាក់ ត្រូវមានរូបសញ្ញានគរបាលជាតិ( រាជសីហ៍) និងមានសរសេរឈ្មោះអង្គភាពប្រើប្រាស់ព្រមទាំងអក្សរឡាតាំង (POLICE) ពីខាងក្រៅជារង្វង់ស្វែងក្របីតាមទំហំសមស្របនៅទ្វារមុខទាំងសងខាងនៃយានយន្ត ។ យានយន្តនិងជលយានទាំងនេះត្រូវបានលាបពណ៌ពិសេស តាមការកំណត់របស់ក្រសួងមហាផ្ទៃ ។

៤.២. ក្រសួងមហាផ្ទៃប្រគល់សិទ្ធិអោយអគ្គស្នងការដ្ឋាននគរបាលជាតិ កំណត់កាលបរិច្ឆេទនៃការផ្លាស់ប្តូរប័ណ្ណសំគាល់ ចេញផ្លាកលេខថ្មីដល់យានយន្តនិងជលយានគ្រប់ប្រភេទ ដូចបានកំណត់ក្នុងប្រការ ១ និង ធ្វើបទដ្ឋានផ្សេងៗទៀតតាមការចាំបាច់ ព្រមទាំងធ្វើការត្រួតពិនិត្យការអនុវត្តប្រកាសនេះអោយមានប្រសិទ្ធិភាព ។

៤.៣. អគ្គស្នងការដ្ឋាននគរបាលជាតិ ត្រូវជំរុញកិច្ចសហការជាមួយក្រសួងសាធារណការនិងដឹកជញ្ជូន និងក្រសួងការពារជាតិអោយបានល្អនិងទាន់ពេលវេលា ក្នុងការប្រមូលពតិមានទិន្នន័យនៃការផ្តល់ប័ណ្ណសំគាល់យានយន្ត ជលយាននិងផ្លាកលេខ ដូចមានចែងក្នុងមាត្រា ៥ , មាត្រា ៦ នៃអនុក្រឹត្យលេខ៧៧អនក្របក ចុះថ្ងៃទី ២៨ ខែវិច្ឆិកា ឆ្នាំ ២០០៣ ដើម្បីបំរើដល់ការគ្រប់គ្រងសន្តិសុខ និងសណ្តាប់ធ្នាប់សាធារណៈ ។

